ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆមាសទី ១
# និង
# ទិសដៅការងារឆមាសទី ២
# ឆ្នាំ២០១១

# អារម្ភកថា

គិតត្រឹមឆមាសទី១ ឆ្នាំ២០១១ នេះ សេដ្ឋកិច្ចពិភពលោកកំពុងឈានទៅរកកំណើនប្រកបដោយចីរភាពខ្លួនឯង[១] ។ ប្រទេសកំពុងអភិវឌ្ឍន៍មានកំណើនរឹងមាំ ហើយសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កំពុងងើបឡើងវិញជាបណ្តើរៗ ។ ប៉ុន្តែ ទោះបីជាស្ថានភាពសេដ្ឋកិច្ចពិភពលោកបានបង្ហាញសញ្ញាណរឹងមាំក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលតម្រូវឲ្យអ្នករៀបចំគោលនយោបាយ និងអ្នកសម្រេចចិត្តផ្នែកនយោបាយបន្តយកចិត្តទុកដាក់ និងខិតខំស្វែងរកដំណោះស្រាយទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត ។

ប្រទេសអភិវឌ្ឍន៍ជាច្រើននៅតែប្រឈមបញ្ហាមួយចំនួនដូចជា ការគរពូនបំណុលសាធារណៈកម្រិតខ្ពស់ជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះប្រជាជន/គ្រឹះស្ថានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ អតុល្យភាពហិរញ្ញវត្ថុកំពុងលេចឡើងជាថ្មី ស្ថានភាពសារពើពន្ធនៅមានភាពទន់ខ្សោយ ការបន្តអនុវត្តនយោបាយរូបិយវត្ថុបន្ធូរបន្ថយយូរពេកកំពុងគំរាមកំហែងដល់ស្ថិរភាពថ្លៃ និងការធ្វើកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុមិនទាន់បានបញ្ចប់ និងមិនទាន់បានអនុវត្តពេញលេញនៅឡើយ ។ នៅប្រទេសកំពុងអភិវឌ្ឍន៍វិញ កំណើនតម្រូវការ និងថ្លៃទ្រព្យសកម្មកើនឡើងលឿនពេក អាចធ្វើឲ្យប្រទេសមួយចំនួនជួបនឹងហានិភ័យនៃអតុល្យភាព ដែលប្រទេសអភិវឌ្ឍន៍ធ្លាប់ជួបប្រទះមុនពេលមានវិបត្តិសេដ្ឋកិច្ច ។ កំណើនដ៏លឿននេះអាចបណ្តាលឲ្យសេដ្ឋកិច្ចឈានទៅរកការកើនឡើងកម្តៅ (overheating) ។ ទន្ទឹមនឹងនោះ សម្ពាធនៃការឡើងថ្លៃទំនិញ និងម្ហូបអាហារ គួបផ្សំនឹងការកើនឡើងថ្លៃប្រេងនៅដើមឆ្នាំ២០១១ ដែលបណ្តាលមកពីភាពតានតឹងខាងនយោបាយ និងសេដ្ឋកិច្ចនៅតំបន់អាហ្វ្រិកខាងជើង និងមជ្ឈិមបូព៌ា បានបង្កឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។

តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅខែមិថុនា ឆ្នាំ២០១១ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថា នឹងថយចុះមកត្រឹម ៤,៣% ក្នុងឆ្នាំ២០១១ ធៀបនឹង ៥,៥% ក្នុងឆ្នាំ២០១០ ។ នៅឆ្នាំ២០១១ នេះ ប្រទេសអភិវឌ្ឍន៍រំពឹងថានឹងមានកំណើនសេដ្ឋកិច្ចក្នុងកម្រិត ២,២% និងអត្រាអតិផរណា ២,៦% ខណៈដែលបណ្តាប្រទេសកំពុងងើបឡើង និងកំពុងអភិវឌ្ឍន៍ មានកំណើនសេដ្ឋកិច្ច ៦,៦% និងអត្រាអតិផរណា ៦,៩% ។ ចំណែកឯប្រទេសចិន ត្រូវបានរំពឹងថានឹងមានកំណើន ៩,៦% ឥណ្ឌា ៨,២% និងអាស៊ានធំ៥ ៥,៤% ។

ដោយឡែក សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឲ្យកត់សម្គាល់ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗមួយចំនួន បន្ទាប់ពីរងការថយចុះដោយសារវិបត្តិក្នុងឆ្នាំ២០០៩ ។ នៅឆ្នាំ២០១១ នេះ កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងប្រមាណជាង ៦% បើធៀបនឹងកម្រិត ៦% នាឆ្នាំ២០១០ ដែលបានទ្រទ្រង់ដោយកំណើនក្នុងវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស ។ ចំណែកឯអតិផរណានៅឆ្នាំ២០១១ ត្រូវបានរំពឹងថានឹងស្ថិតក្នុងកម្រិតមួយខ្ពង់ ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានខិតខំបន្តបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន និងខិតខំចូលរួមពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។ នៅក្នុងឆមាសទី ១

[១] ឯកសាររបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១១

ឆ្នាំ២០១១ អត្រាអតិផរណាបានកើនឡើងសន្សឹមៗពី ៣,៣% នៅខែមករា ដល់ ៥,១% នៅខែមិថុនា ដែលស្ថិតនៅក្នុងកម្រិតអាចគ្រប់គ្រងបាន ។ ដោយផ្អែកលើអត្រាប្តូរប្រាក់ទីផ្សារចុងគ្រា នៅក្នុងអំឡុងពេលដូចគ្នានេះ ប្រាក់រៀលបានឡើងថ្លៃ ៤% ធៀបនឹងខែមិថុនា ឆ្នាំ២០១០ និងចុះថ្លៃ ១,១% ធៀបនឹងខែធ្នូ ឆ្នាំ២០១០ ។

គិតត្រឹមឆមាសទី ១ ឆ្នាំ២០១១ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ចំនួន ២.៩១២,៧ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានប្រមាណ ៤ខែ ។ ចំពោះការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានអនុវត្តដោយឈរលើមូលដ្ឋានប្រុងប្រយ័ត្ន គឺសុវត្ថិភាព និងសាច់ប្រាក់ងាយស្រួលជាចម្បង ។

ទន្ទឹមនឹងការរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល និងសម្រេចបានលទ្ធផលល្អប្រសើរ ។ លទ្ធផលនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យធនាគារ ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ហើយបានបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។

វិធានការពង្រឹងគុណភាពប្រព័ន្ធធនាគារ ដែលបានផ្តួចផ្តើមឡើងនៅឆ្នាំ២០០៩-២០១០ សម្រេចបានលទ្ធផលជាទីពេញចិត្ត ។ ការបង្កើនដើមទុនអប្បបរមារបស់គ្រឹះស្ថានធនាគារត្រូវបានបញ្ចប់ដោយរលូន ។ រីឯយន្តការជំរុញអភិបាលកិច្ចសាជីវកម្មក្នុងប្រព័ន្ធធនាគារក៏ត្រូវបានរៀបចំឡើង ។ ទន្ទឹមនោះ សមត្ថភាពត្រួតពិនិត្យធនាគារក៏ត្រូវបានពង្រឹងបន្ថែមទៀត ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃវិស័យធនាគារក្នុងប្រទេស ។ ក្នុងការពង្រឹងការគ្រប់គ្រងហានិភ័យ និងការជំរុញការផ្តល់ឥណទានក្នុងសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំហើយផងដែរនូវក្របខ័ណ្ឌបទប្បញ្ញត្តិសំខាន់ៗសម្រាប់ដំណើរការ "ការិយាល័យឥណទាន" ឯកជននៅក្នុងប្រទេសកម្ពុជា ។ ការិយាល័យនេះរំពឹងថានឹងអាចដំណើរការក្នុងឆ្នាំខាងមុខ ។

ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ រូបិយវត្ថុទូទៅមានកំណើន ១២,៩% ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារបានកើន ៨,៣% និងទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារបានកើន ៤១% ។ ចំណែកឯទំហំប្រតិបត្តិការវិញ ឥណទានសរុបនិងប្រាក់បញ្ញើបានកើនឡើង ២៤,៨% និង ១៨,៩% រៀងគ្នានៅខែមេសា ឆ្នាំ២០១១ ធៀបនឹងខែធ្នូ ឆ្នាំ២០១០ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន បានធ្វើឲ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់ ពី ៦% មកត្រឹម ប្រហែល ៣% នៃឥណទានសរុប ។

វិស័យមីក្រូហិរញ្ញវត្ថុ ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។វិស័យនេះមានការរីកចម្រើនយ៉ាងខ្លាំង និងមានហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានពង្រីកជាលំដាប់ទៅដល់ជនបទ ។ ឥណទានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុមានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងឆមាសទី ១ ឆ្នាំ២០១១ ដោយឥណទានសរុបបានកើនឡើង ១១,៨% និងចំនួនអតិថិជនកើនឡើង ១% ធៀបនឹងឆ្នាំ២០១០ ។ ចំពោះប្រាក់បញ្ញើវិញ បានកើនឡើង ១១,៥% និងចំនួនអ្នកផ្ញើប្រាក់កើនឡើង ១១,២% ។ ការកើនឡើងនេះបានរួមចំណែកអភិវឌ្ឍន៍អាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ហើយបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាចុះត្រួតពិនិត្យដល់ទីកន្លែង និងលើឯកសារ សំដៅជួយពង្រឹងអភិបាលកិច្ចល្អ និងភាពរឹងមាំនៃប្រព័ន្ធធនាគារ ។ នៅឆមាសទី១ ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៥ ។ ជារួម ប្រព័ន្ធធនាគារមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ ដោយបានអនុវត្តតាមបទប្បញ្ញត្តិ និងវិធានការប្រុងប្រយ័ត្ន ទោះបីជាមានធនាគារមួយចំនួននៅមានចំណុចខ្វះខាតក៏ដោយ ក៏យើងបានផ្តល់អនុសាសន៍ឲ្យកែតម្រូវរួចហើយ ។

ដោយវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងប្រព័ន្ធធនាគារមានការរីកចម្រើនជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ និងដើម្បីឲ្យស្របតាមនិន្នាការនៃសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានសម្រេចកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន ដោយបង្កើតអគ្គនាយកដ្ឋានបច្ចេកទេស និងអគ្គនាយកដ្ឋានត្រួតពិនិត្យ សំដៅពង្រឹងយន្តការការងារបច្ចេកទេស និងការងារត្រួតពិនិត្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពថែមទៀត ។

ដោយឡែក ចំពោះការពង្រឹងប្រតិបត្តិការនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ធនាគារជាតិនៃកម្ពុជាបន្តចូលរួមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី ២ ឲ្យកាន់តែមានប្រសិទ្ធភាព និងបានដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (Core banking system) នៅតាមសាខាដែលនៅសល់ចំនួន ១០ ដើម្បីពង្រឹងតម្លាភាព ជួយសម្រួលនិងពន្លឿនប្រតិបត្តិការបើក-ដាក់ប្រាក់ការបង់ពន្ធ និងការផ្ទេររវាងគណនី ។

ក្រៅពីនេះ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាតិទូទាត់សងប្រាក់ត្រូវបានបន្តអភិវឌ្ឍ ក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីរៀបចំប្រព័ន្ធទូទាត់និងផាត់ទាត់ ហើយគ្រោងនឹងដាក់ឲ្យប្រើប្រាស់នៅដើមឆ្នាំ២០១២ ។ តាមរយៈគម្រោងអភិវឌ្ឍន៍ប្រព័ន្ធពេញលេញនេះ ព័ត៌មាននៃការផាត់ទាត់និងទូទាត់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដូចជា មូលប្បទានបត្រ និងបញ្ជាទូទាត់ នឹងត្រូវបានប្រមូលផ្តុំនៅទីស្នាក់ការកណ្តាលរបស់ធនាគារជាតិនៃកម្ពុជា ។

ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្តាធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអន្តរជាតិចំនួន ២ គឺ ១)-កិច្ចប្រជុំថ្នាក់ទេសាភិបាលរង និងអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី ៤ និង ២)-កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិស៊ាសិន (SEACEN EXCO) លើកទី ៥ ដែលធនាគារជាតិនៃកម្ពុជាធ្វើជាប្រធានដឹកនាំអង្គប្រជុំ ។ នៅក្នុងឆមាសទី ១ នេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំងលើកទី ១៨ នៅខេត្តសៀមរាប ដោយមានប្រទេសចំនួន ២០ មកពីទ្វីបអឺរ៉ុប អាហ្វ្រិក និងអាស៊ីបានចូលរួមក្នុងគោលបំណងរឹតចំណងមិត្តភាព និងសហប្រតិបត្តិការជាមួយធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង ។ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក នៅតែជាស្ថាប័នសំខាន់ក្នុងការផ្តល់ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលដល់ធនាគារជាតិនៃកម្ពុជាដែលក្រសោបទៅលើផ្នែកសំខាន់ៗ ដូចជា ការត្រួតពិនិត្យធនាគារ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងប្រព័ន្ធទូទាត់ ជាដើម ។

លើសពីនេះទៀត ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសិក្សា និងរៀបចំវិធីសាស្ត្រ គោលនយោបាយ និងយន្តការសហប្រតិបត្តិការ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល សំដៅចូលរួមអនុវត្តគោលនយោបាយធ្វើបដិដុល្លាររូបនីយកម្មរបស់រាជរដ្ឋាភិបាល ។ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងភារកិច្ចធនាគារកណ្តាលឲ្យកាន់តែមានប្រសិទ្ធភាព និងសម្រេចបានគោលដៅដែលបានគ្រោង ធនាគារជាតិនៃកម្ពុជាបានរៀបចំផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ លើផ្នែកត្រួតពិនិត្យគ្រឹះស្ថានធនាគារ ការពង្រឹងការអនុវត្តនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភ្នាក់ងារប្រតិបត្តិនៃគម្រោងជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយមានកិច្ចសហការដ៏ជិតស្និទ្ធ និងការចូលរួមដ៏សកម្មពីសំណាក់ស្ថាប័នពាក់ព័ន្ធទាំងឡាយ ជាពិសេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មការមូលបត្រកម្ពុជា បាននិងកំពុងរៀបចំធ្វើបច្ចុប្បន្នកម្ម "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" របស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងដំណើរការរីកចម្រើននៃវិស័យហិរញ្ញវត្ថុក្នុងប្រទេស ព្រមទាំងតម្រូវការថ្មីក្នុងកាលៈទេសៈនៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ។

ជារួម ជាមួយនឹងការខិតខំប្រកបដោយការប្តេជ្ញាចិត្តរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ និងការគាំទ្រប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាពិសេស រាជរដ្ឋាភិបាល និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងឡាយ ប្រតិបត្តិការឆមាសទី១ ឆ្នាំ២០១១ នេះ បានសម្រេចលទ្ធផលល្អប្រសើរ ។ ខ្ញុំសូមសម្តែងការអរគុណដ៏ជ្រាលជ្រៅដល់ក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមវិភាគទានដ៏មានតម្លៃ ក្នុងការសម្រេចបាននូវជោគជ័យទាំងអស់នេះ ។

**ទេសាភិបាល**

# មាតិកា

* * *


ក- របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១១ ១

សេចក្តីផ្តើម ២

I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល ៣

១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា ៣

១.២- ស្ថានភាពអត្រាប្តូរប្រាក់ ៥

១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៥

១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន ៧

១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណមួយចំនួន ៨

២- ការវិវត្តរូបិយវត្ថុ ៨

២.១- ការផ្គត់ផ្គង់រូបិយវត្ថុ ៩

២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ១០

២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ១០

២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ១២

២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ១២

៣- ជញ្ជីងទូទាត់ ១៤

៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១៤

៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ ១៥

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៦

៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ ១៦

៤.២- គោលការណ៍វិនិយោគទុនបម្រុងអន្តរជាតិ ១៦

៤.៣- សភាពការណ៍ទីផ្សារវិនិយោគទុនបម្រុងអន្តរជាតិ ១៦

៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៧

៥.១- ការត្រួតពិនិត្យគ្រឹះ ស្ថានធនាគារ និងហិរញ្ញវត្ថុ ១៨

៥.១.១- ការត្រួតពិនិត្យលើឯកសារ ១៨

៥.១.២- ការត្រួតពិនិត្យដល់ទីកន្លែង ១៩

៥.១.៣- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៩

៥.២- ការងារនីតិកម្ម ២០

៥.៣- ការងារផ្តល់អាជ្ញាប័ណ្ណ និងជម្រះបញ្ជី ២០

៦- ការផ្គត់ផ្គង់សេវាកម្មធនាគារកណ្តាល ២០

៦.១- សេវាកម្មគ្រប់គ្រងគណនី ២០

៦.១.១- ចំពោះស្ថាប័នរដ្ឋ ២១

៦.១.២- ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២១

៦.២- សេវាកម្មផ្ទេរប្រាក់ក្នុងប្រទេស ២១

៦.៣- សេវាកម្មផាត់ទាត់មូលប្បទានបត្រ ២១

៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ២១

៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក ២២

៦.៤- ការងារឥណទាន ២២

៦.៥- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល ២២

៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ២៣

៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់ ២៤

៩- ការងារព័ត៌មានវិទ្យា ២៥

II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៥

១- សកម្មភាពក្រុមប្រឹក្សាភិបាល ២៥

២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ២៦
២.១- ស្ថិតិមន្ត្រីបុគ្គលិក ២៦
២.២- ការងារបណ្តុះបណ្តាល ២៦
៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៧
៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៨
III- ទំនាក់ទំនងអន្តរជាតិ ២៨
១- ទំនាក់ទំនងពហុភាគី ២៨
១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ២៨
១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ២៩
១.៣- ទំនាក់ទំនងជាមួយអាស៊ាន ២៩
១.៣.១- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ២៩
១.៣.២- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ ៣០
១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន - SEACEN) ៣០
១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន - Francophone) ៣១
២- ទំនាក់ទំនងទ្វេភាគី ៣១
សន្និដ្ឋាន ៣៣
ខ- ទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ ៣៥
១- ការងាររូបិយវត្ថុ ៣៦
២- ការងារប្តូរប្រាក់ និងការគ្រប់គ្រងទុនបម្រុង ៣៦
៣- ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ៣៦
៤- ការងារត្រួតពិនិត្យ ៣៧
៥- ការងារប្រតិបត្តិការ ៣៧

៦- **ការងារបោះផ្សាយ និងឃ្លាំងបេឡា** ៣៧

៧- **ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច** ៣៧

៨- **ការងារព័ត៌មានវិទ្យា** ៣៧

៩- **ការងារបណ្តុះបណ្តាល** ៣៨

១០- **ទំនាក់ទំនងអន្តរជាតិ** ៣៨

**ឧបសម្ព័ន្ធ** ៣៩

**ឧបសម្ព័ន្ធ ១ ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា** ៤០

**ឧបសម្ព័ន្ធ ២ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ** (អត្រាទិញចុងខែ) ៤១

**ឧបសម្ព័ន្ធ ៣ ស្ថានភាពរូបិយវត្ថុ** (គិតជាពាន់លានរៀល) ៤២

**ឧបសម្ព័ន្ធ ៤ ស្ថានភាពរូបិយវត្ថុ** (បម្រែបម្រួលប្រចាំខែជាភាគរយ) ៤៣

**ឧបសម្ព័ន្ធ ៥ តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា** ៤៤

**ឧបសម្ព័ន្ធ ៦ តារាងគណនីវិភាគធនាគារពាណិជ្ជ** ៤៥

**ឧបសម្ព័ន្ធ ៧ ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច** ៤៦

**ឧបសម្ព័ន្ធ ៨ ជញ្ជីងទូទាត់ប្រទេសកម្ពុជា** (ឆ្នាំ២០០៨ ដល់ ឆមាសទី ១ ឆ្នាំ២០១១) ៤៧

# ក- របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១១

## សេចក្តីផ្តើម

នៅក្នុងឆមាសទី ១ ឆ្នាំ២០១១ ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក កំពុងបន្តមានភាពប្រសើរ ទោះបីជាមិនទាន់បានត្រឡប់មករកកម្រិតដូចគ្រាមុនពេលមានវិបត្តិក៏ដោយ ។ បរិបទនេះ បានឆ្លុះបញ្ចាំង ឲ្យឃើញនូវសញ្ញាណជាវិជ្ជមាននិងការបន្តងើបឡើងវិញចំពោះសេដ្ឋកិច្ចកម្ពុជាផងដែរ ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដាក់ចេញនូវវិធានការជាប្រព័ន្ធមួយចំនួន សំដៅទប់ស្កាត់វិបត្តិផ្សេងៗ និងបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្ន ដើម្បីស្តារឡើងវិញនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្រោយពីបានទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុ ។

នៅឆមាសទី១ នេះ សេដ្ឋកិច្ចកម្ពុជាបានបន្តរក្សាស្ថានភាពល្អប្រសើរដែលគួរកត់សម្គាល់តាំងពីឆ្នាំ ២០១០ មក និងមានស្ថិរភាពជាបង្គួរ ។ បើតាមការព្យាកររបស់រាជរដ្ឋាភិបាល កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងកើនឡើងលើសពី ៦% បើធៀបនឹង ៦% នាឆ្នាំ២០១០ ខណៈដែលមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា កំណើនសេដ្ឋកិច្ចកម្ពុជានឹងមាន ៦,៨% ។ កំណើននេះទ្រទ្រង់ដោយកំណើនវិស័យទេសចរណ៍ ការនាំចេញ វិនិយោគផ្ទាល់បរទេស និងវិស័យកសិកម្ម ។

បើពិនិត្យជារួមទៅលើអត្រាអតិផរណាឆ្នាំលើឆ្នាំរយៈពេល ៦ខែ ចុងក្រោយនេះ ឃើញថាមានលំនឹងសមរម្យបង្គួរ ដោយអត្រាអតិផរណាមធ្យមឆ្នាំលើឆ្នាំមានកម្រិតមួយខ្ទង់ ។ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ក្នុងរយៈពេល ៦ ខែ ដើមឆ្នាំ២០១១ នេះ បានរក្សាស្ថិរភាពគួរឲ្យកត់សម្គាល់ ដោយបានប្រែប្រួលក្នុងរង្វង់ ១% ។

បើទោះបីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានភាពល្អប្រសើរឡើងវិញក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែបន្តចាត់វិធានការ និងគោលនយោបាយប្រុងប្រយ័ត្ន សំដៅកាត់បន្ថយបច្ច័យអាក្រក់ពីវិបត្តិផ្សេងៗដែលអាចនឹងកើតមានឡើងជាយថាហេតុ ។ ក្នុងបរិការណ៍នេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុយ៉ាងប្រុងប្រយ័ត្នដោយផ្អែកលើទស្សនវិស័យអនាគតនៃសេដ្ឋកិច្ច និន្នាការអតិផរណា និងការសម្របសម្រួលជាមួយនយោបាយសារពើពន្ធ ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានៅតែបន្តពង្រឹង និងកែទម្រង់ក្របខ័ណ្ឌច្បាប់ ដើម្បីពង្រឹងគោលនយោបាយអភិបាលកិច្ច និងសុខភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានចេញប្រកាស និងបទប្បញ្ញត្តិមួយចំនួនដូចជា ការតាមដានហានិភ័យឥណទានធំ ការរៀបចំកិច្ចព្រមព្រៀងមេ (Master Agreement) សម្រាប់ប្រតិបត្តិការទិញយកវិញ (Repo) និងកំពុងរៀបចំអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ជាតិ ។ ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តពង្រឹងការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ និងបញ្ញត្តិករ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍជាសកលនៃបទដ្ឋានអន្តរជាតិក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។

# I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

### ១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា

ស្របពេលដែលសេដ្ឋកិច្ចពិភពលោកនាឆ្នាំ២០១១ នេះ ត្រូវបានរំពឹងថានឹងមានកំណើន ៤,៣% បន្ទាប់ពីមានកំណើន ៥,៣% នៅឆ្នាំ២០១០ តម្រូវការប្រើប្រាស់ជាសកល ក៏មានការកើនឡើងផងដែរ ដែលជាមូលហេតុធ្វើឲ្យអត្រាអតិផរណាក្នុងតំបន់នានា រួមទាំងតំបន់អាស៊ីមានការកើនឡើង ជាពិសេសកំណើនថ្លៃស្បៀងអាហារ និងប្រេងឥន្ធនៈក្នុងទីផ្សារពិភពលោកនា៦ខែដើមឆ្នាំនេះ ។ ដោយឡែក ប្រទេសកម្ពុជាដែលមានសេដ្ឋកិច្ចតូចនិងបើកចំហ ហើយទំនិញប្រើប្រាស់មួយភាគធំជាទំនិញនាំចូលផងនោះ ពិតជាមិនអាចគេចផុតពីការទទួលរងនូវសម្ពាធអតិផរណានោះបានឡើយ ។ ទន្ទឹមនោះ ប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាក៏មានអត្រាអតិផរណាខ្ពស់ផងដែរ ដូចជា ប្រទេសវៀតណាម ២០,៨% ចិន ៥,៥% កូរ៉េខាងត្បូង ៤,៤% និងថៃ ៤,១% ។ ប៉ុន្តែ ដោយបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសមស្រប ពិសេសគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា សម្ពាធអតិផរណាទាំងនេះត្រូវបានកាត់បន្ថយ ហើយស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ដោយរក្សាបាននូវអត្រាអតិផរណាត្រឹមកម្រិត ១ខ្ទង់ ព្រមទាំងមាននិន្នាការនឹងនរបង្គួរទៀតផង ។

ក្រាហ្វស្ថិតិ ១ : **អតិផរណាឆ្នាំលើឆ្នាំ**




ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំឃើញថា នាដំណាច់ឆមាសទី១ ឆ្នាំ២០១១ នេះ អតិផរណាមានអត្រា ៦,៤% ដែលជាអត្រាខ្ពស់ជាងគ្រាដូចគ្នានាឆ្នាំ២០១០ និងឆ្នាំ២០០៩ ដែលមានកម្រិតត្រឹម ២,៦% និង -៤,៩% រៀងគ្នា ។ ប៉ុន្តែ ទោះបីជានាដំណាច់ឆមាសទី១ នេះ អតិផរណាមានអត្រាខ្ពស់ជាងគ្រាដូចគ្នានា ២ឆ្នាំមុនក៏ដោយ ក៏អត្រាមធ្យម ៦ខែ ដើមឆ្នាំនេះ មានកម្រិតត្រឹម ៤,៩% គឺទាបជាងអត្រាមធ្យម ៦ខែ នាដើមឆ្នាំ២០១០ ដែលមានកម្រិត ៥,៥% ។

ក្រាហ្វស្ថិតិ ២ : **ក្រុមមុខទំនិញដែលឡើងថ្លៃខ្លាំងជាងគេក្នុងឆមាសទី១ ឆ្នាំ២០១១** (ឆ្នាំលើឆ្នាំ)




និន្នាការកើនឡើងនៃអត្រាអតិផរណាឆ្នាំលើឆ្នាំនាឆមាសទី១នេះ ឆ្លុះបញ្ចាំងនូវការកើនឡើងយ៉ាងខ្លាំងនៃសន្ទស្សន៍ថ្លៃក្រុមភោជនីយដ្ឋានចំនួន ១១,២% និងដឹកជញ្ជូនចំនួន ៨,៥% គួបផ្សំជាមួយនឹងការកើនឡើងសន្ទស្សន៍ថ្លៃក្រុមទំនិញនិងសេវាផ្សេងៗចំនួន ៨,៤% ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀតចំនួន ៦,១% ម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងចំនួន ៦,១% គមនាគមន៍ចំនួន ២,២% គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ ២,៤% សម្លៀកបំពាក់ និងស្បែកជើងចំនួន ២,៤% សុខាភិបាលចំនួន ១,៩% និងក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ចំនួន ០,៥% និងក្រុមការសិក្សាចំនួន ០,២% ខណៈដែលសន្ទស្សន៍ថ្លៃក្រុមការកម្សាន្តនិងវប្បធម៌ថយចុះចំនួន១,៦% ។ ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូនត្រូវបានឆ្លុះបញ្ចាំងដោយការឡើងថ្លៃប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងម៉ាស៊ីន និងសេវាដឹកជញ្ជូន ។ ចំណែកឯការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹងដែលមានមេគុណធំជាងគេក្នុងចំណោមក្រុមទំនិញទាំងអស់ គឺបណ្តាលមកពីការកើនឡើងថ្លៃត្រី សាច់ជ្រូក សាច់មាន់ អង្ករ និងបន្លែ ។

ក្រាហ្វស្ថិតិ ៣ : **ការរួមចំណែកក្នុងអតិផរណា** (ឆ្នាំលើឆ្នាំ)



ក្នុងឆមាសទី១នេះ អតិផរណាមានអត្រា ៦,៤% ក្នុងនោះក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងមានចំណែក ៣,១% (ត្រូវនឹងសមាមាត្រ ៤៧,៧% នៃអតិផរណារួម) ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈដទៃទៀតមានចំណែក ១% (ត្រូវនឹងសមាមាត្រ ១៦,២% នៃអតិផរណារួម) ក្រុមដឹកជញ្ជូនមានចំណែក ១% (ត្រូវនឹងសមាមាត្រ ១៦,១% នៃអតិផរណារួម) និងក្រុមភោជនីយដ្ឋាន មានចំណែក ០,៧% (ត្រូវនឹងសមាមាត្រ ១០,២% នៃអតិផរណារួម) ខណៈដែល ៨ ក្រុមទៀតដែលនៅសល់មានត្រឹមតែ ០,៤% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ ៥,៧% នៃអតិផរណារួម) ។

ក្រាហ្វស្ថិតិ ៤ : **អតិផរណាមិនរាប់បញ្ចូលក្រុមទំនិញសំខាន់ៗ** (ឆ្នាំលើឆ្នាំ)




នាដំណាច់ឆមាសទី១ នេះ អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមម្ហូបអាហារមានកម្រិត ៤,៧% ខណៈដែលអត្រាអតិផរណារួមមាន ៦,៤% ដែលបង្ហាញថា បម្រែបម្រួលថ្លៃទំនិញក្រុមម្ហូបអាហារមានឥទ្ធិពលជាបង្គួរទៅលើកំណើនអតិផរណារួមធៀបនឹងក្រុមដទៃទៀត ពោលគឺក្រុមម្ហូបអាហារបានរុញឲ្យអតិផរណាកើនឡើង ។ ចំណែកឯអតិផរណាមិនរាប់បញ្ចូលក្រុមដឹកជញ្ជូន (មានបញ្ចូលទាំងថ្លៃប្រេងឥន្ទនៈ) មានកម្រិត ៦% គឺទាបជាងអតិផរណារួមបន្តិចបន្តួច ដែលឆ្លុះបញ្ចាំងឲ្យឃើញថា ថ្លៃទំនិញក្រុមដឹកជញ្ជូនមិនសូវមានឥទ្ធិពលធ្វើឲ្យអតិផរណារួមខ្ពស់ឡើងនោះទេ ។

### ១.២- ស្ថានភាពអត្រាប្តូរប្រាក់

#### ១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកគិតជាមធ្យមប្រចាំខែ បានធ្លាក់ចុះជាបន្ត បន្ទាប់ ពី ៤.១៩៨ រៀល ក្នុង ១ដុល្លារអាមេរិក នាខែធ្នូ ឆ្នាំ២០១០ មក ៤.០១១ រៀល ក្នុង ១ដុល្លារអាមេរិក នាខែមេសា ។ នេះសរឲ្យឃើញថា ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ។ ការឡើងថ្លៃនៃប្រាក់រៀលក្នុងអំឡុង ៤ខែ ដើមឆ្នាំ២០១១ នេះ បណ្តាលមកពីតម្លៃប្រាក់ដុល្លារនៅលើទីផ្សារអន្តរជាតិបានចុះថោកធៀបនឹងរូបិយប័ណ្ណផ្សេងៗ ជាពិសេសធៀបនឹងរូបិយប័ណ្ណនៃប្រទេសជា

ដែគូពាណិជ្ជកម្មរបស់កម្ពុជា គួបផ្សំនឹងកំណើនតម្រូវការប្រាក់រៀលសម្រាប់ការងារប្រមូលកសិផល និងតម្រូវការចាយវាយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ។ បន្ទាប់មកប្រាក់រៀលបានធ្លាក់ថ្លៃសន្សឹមៗរហូតដល់ ៤.១០៥ រៀល ក្នុង ១ដុល្លារអាមេរិក នាខែមិថុនា ឆ្នាំ២០១១ ។ នេះបណ្តាលមកពីតម្រូវការប្រាក់រៀលបានថយមកវិញ បន្ទាប់ពីរដូវប្រមូលផលបានកន្លងផុត ។

ផ្អែកលើអត្រាទិញទីផ្សារចុងគ្រា អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះពី ៤.២៦៦ រៀល ក្នុង ១ ដុល្លារអាមេរិក នាដំណាច់ខែមិថុនា ឆ្នាំ២០១០ មក ៤.១២២ រៀល ក្នុង ១ ដុល្លារអាមេរិក នាដំណាច់ឆមាសទី១ ឆ្នាំ២០១១ ពោលគឺប្រាក់រៀលបានឡើងថ្លៃ ៣,៤% (អត្រាឆ្នាំលើឆ្នាំ) ប៉ុន្តែបើធៀបនឹងខែធ្នូ ឆ្នាំ២០១០ ប្រាក់រៀលបានចុះថ្លៃ ១,៨% ។

| | អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម |
| មិថុនា-១០ | ៤.២៦៦ | ៤.២៧៥ | ៤.២៧១ | ៤.២២២ | ៤.២៣០ | ៤.២២៦ |
| កក្កដា-១០ | ៤.២៦០ | ៤.២៧៣ | ៤.២៦៧ | ៤.២៣៧ | ៤.២៤៥ | ៤.២៤១ |
| សីហា-១០ | ៤.២៥៧ | ៤.២៦៧ | ៤.២៦២ | ៤.២៣៥ | ៤.២៤៣ | ៤.២៣៩ |
| កញ្ញា-១០ | ៤.២៤៥ | ៤.២៥៣ | ៤.២៤៩ | ៤.២២៧ | ៤.២៣៥ | ៤.២៣១ |
| តុលា-១០ | ៤.២១៦ | ៤.២២៤ | ៤.២២០ | ៤.២២២ | ៤.២៣០ | ៤.២២៦ |
| វិច្ឆិកា-១០ | ៤.០៧៤ | ៤.០៨១ | ៤.០៧៨ | ៤.០៧៥ | ៤.០៨៣ | ៤.០៧៩ |
| ធ្នូ-១០ | ៤.០៤៨ | ៤.០៥៣ | ៤.០៥១ | ៤.០៥១ | ៤.០៥៥ | ៤.០៥៣ |
| មករា-១១ | ៤.០៥២ | ៤.០៥៩ | ៤.០៥៦ | ៤.០៥០ | ៤.០៥៤ | ៤.០៥២ |
| កុម្ភៈ-១១ | ៤.០៣៤ | ៤.០៣៨ | ៤.០៣៦ | ៤.០៣៦ | ៤.០៤២ | ៤.០៣៩ |
| មីនា-១១ | ៤.០០៤ | ៤.០១០ | ៤.០០៧ | ៤.០០៧ | ៤.០១៣ | ៤.០១០ |
| មេសា-១១ | ៤.០៦០ | ៤.០៦៩ | ៤.០៦៥ | ៤.០២០ | ៤.០២៨ | ៤.០២៤ |
| ឧសភា-១១ | ៤.០៩៤ | ៤.១០៣ | ៤.០៩៩ | ៤.០៨០ | ៤.០៨៨ | ៤.០៨៤ |
| មិថុនា-១១ | ៤.១២២ | ៤.១២៧ | ៤.១២៥ | ៤.១១៥ | ៤.១២៣ | ៤.១១៩ |

បើពិនិត្យលើអត្រាមធ្យមប្រចាំឆមាស ប្រាក់រៀលបានឡើងថ្លៃ ៣,៧% នាឆមាសទី១ ឆ្នាំនេះ ធៀបនឹងគ្រាដូចគ្នានៃឆ្នាំកន្លងទៅ ប៉ុន្តែបើធៀបនឹងឆមាសទី២ នៃឆ្នាំ២០១០ ប្រាក់រៀលបានឡើងថ្លៃ ៣,៣% ។ ក្នុងឆមាសទី១ នេះ អត្រាប្តូរមធ្យមប្រចាំខែមានកម្រិតទាបបំផុតនៅខែមេសា (៤.០១១រៀល) និងខ្ពស់បំផុតនៅខែមិថុនា (៤.១២២រៀល) ។

ក្រាហ្វស្ថិតិ ៥ : **ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក**
(ឆមាសទី១ ឆ្នាំ២០១១)




**១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**

ការប្រៀបធៀបអត្រាប្តូរប្រាក់រៀលជាមួយរូបិយប័ណ្ណមួយចំនួន ជាពិសេសរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែងបានបង្ហាញថា ក្នុងឆមាសទី១ ឆ្នាំ២០១១ ប្រាក់រៀលបានធ្លាក់ថ្លៃធៀបនឹងប្រាក់អឺរ៉ូ ១០,៥៤% ប្រាក់ដុល្លារអូស្ត្រាលី ៧,១០% ប្រាក់វ៉ុនកូរ៉េ ៦,៩៦% ប្រាក់ដុល្លារសិង្ហបុរី ៦,២៤% ប្រាក់រូពីឥណ្ឌូណេស៊ី ៦,២២% ប្រាក់យ៉ន់ចិន ៣,៩២% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៣,៣៤% ប្រាក់យ៉េនជប៉ុន ២,៦២% ប្រាក់ប៉េសូហ្វីលីពីន ២,២៩% និងប្រាក់ដុល្លារតៃវ៉ាន់ ២,១៦% ប្រាក់ដុល្លារហុងកុង ១,៥៤% ប៉ុន្តែបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ៣,៨៥% ។

ក្រាហ្វស្ថិតិ ៦ : **ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**



### ១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណមួយចំនួន

ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ប្រាក់ដុល្លារអាមេរិកបានចុះថ្លៃធៀបនឹងរូបិយប័ណ្ណមួយចំនួន ដូចជា ប្រាក់អឺរ៉ូ ៨,១០% ប្រាក់ដុល្លារអូស្ត្រាលី ៥,១៣% ប្រាក់វ៉ុនកូរ៉េ ៤,៩៩% ប្រាក់ដុល្លារសឹង្ហបុរី ៤,៤១% ប្រាក់រូពីឥណ្ឌូនេស៊ី ៤,២៨% ប្រាក់ផោនអង់គ្លេស ៣,៩៥% ប្រាក់យ៉ន់ចិន ២,២២% ប្រាក់រីងហ្គីតម៉ាឡេស៊ី ១,៧៦% ប្រាក់យ៉េនជប៉ុន ១,០១% ប្រាក់ប៉េសូហ្វីលីពីន ០,៩៩% ប្រាក់ដុល្លារតៃវ៉ាន់ ០,៨២% និងប្រាក់ដុល្លារហុងកុង ០,០១% ។ ទន្ទឹមនឹងនោះដែរ ប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ៥,៥៤% និងប្រាក់បាតថៃ ២,០៩% ។

ក្រាហ្វិកទី ៧ : **ការវិវត្តនៃតម្លៃប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណមួយចំនួន**




## ២- ការវិវត្តរូបិយវត្ថុ

សេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងឆ្នាំ២០១១ នេះ រំពឹងថានឹងមានអត្រាកំណើនលើសពី ៦% បន្ទាប់ពីបានកើនមកវិញដល់កម្រិត ៦% កាលពីឆ្នាំ២០១០ ។ ការរំពឹងនៃកំណើនសេដ្ឋកិច្ចនាឆ្នាំនេះ អាចឆ្លុះបញ្ចាំងបានតាមរយៈភាពរីកចម្រើននៃប្រព័ន្ធធនាគារ និងអន្តរការិយកម្មហិរញ្ញវត្ថុក្នុងអំឡុងឆមាសទី១ នេះ ផងដែរ ។ ជាក់ស្តែង បរិមាណឥណទានចំពោះវិស័យឯកជនមានកំណើនជាបណ្តើរៗឡើងវិញ ខណៈអត្រាកំណើននៃរូបិយវត្ថុទូទៅ (M2) មានកម្រិតគួរឲ្យកត់សម្គាល់ ដែលក្នុងនោះមានប្រាក់បញ្ញើរបស់និវាសជននៅក្នុងប្រព័ន្ធធនាគារ ជាចំណែកដ៏សំខាន់ផងដែរ ។ ម្យ៉ាងវិញទៀត ទ្រព្យសកម្មបរទេសសុទ្ធ ព្រមទាំងដើមទុនរបស់ប្រព័ន្ធធនាគារនៅតែបន្តរក្សាបានកំណើនជាបង្គួរតទៅទៀត ។ ទាំងអស់នេះ ជាការឆ្លុះបញ្ចាំងនូវកំណើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារទាំងមូល ។

ក្រាហ្វស្ថិតិ ៨ : **ស្ថានភាពរូបិយវត្ថុ**




**២.១- ការផ្គត់ផ្គង់រូបិយវត្ថុ**

ក្នុងអំឡុងឆមាសទី១ នេះ រូបិយវត្ថុទូទៅ (M2) របស់ប្រព័ន្ធធនាគារបានកើនឡើងចំនួន ២.៥៣០,៨ ពាន់លានរៀល (១៣%) ពោលគឺកើនពី ១៩.៤៧៦,៨ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១០ ទៅ ២២.០០៧,៦ ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០១១ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ (M2) ជាចម្បងគឺបណ្តាលមកពីកំ ណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ២.១៩០,១ ពាន់លានរៀល (១៣,៨%) រូបិយវត្ថុក្នុងចរាចរណ៍ចំនួន ២៣៩,៥ ពាន់លានរៀល (៧,៧%) ប្រាក់បញ្ញើមានកាលកំណត់និងសន្សំចំនួន ២១,៨ ពាន់លានរៀល (៥,៣%) និងប្រាក់បញ្ញើចរន្តចំនួន ៧៩,៥ ពាន់លានរៀល (៦៥%) ។ គួរកត់សម្គាល់ផងដែរថា នៅក្នុងប្រាក់បញ្ញើជារូបិយប័ណ្ណសរុប មាន ៤៥% ជាប្រាក់បញ្ញើមានកាលកំណត់ ៣៥% ជាប្រាក់បញ្ញើសន្សំ ១៩% ជាប្រាក់បញ្ញើចរន្ត និង ១% ជាប្រាក់បញ្ញើផ្សេងៗ ។ ប្រាក់បញ្ញើជារូបិយប័ណ្ណមានការកើនឡើងជារៀងរាល់ខែក្នុងអំឡុងឆមាសទី១ នេះ ។

ក្រាហ្វស្ថិតិ ៩ : **សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ**



**តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗនិងសន្ទស្សន៍ថ្លៃទំនិញនិងសេវា**

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ធ្នូ-១០ | មករា-១១ | កុម្ភៈ-១១ | មីនា-១១ | មេសា-១១ | ឧសភា-១១ | មិថុនា-១១ |
|---|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ៥,៦ | ៤,៥ | ៧,៨ | ៩,៣ | ៨,០ | ៧,៩ | ៧,៦ |
| ឥណទានផ្នែកឯកជន | ២៦,៦ | ២៤,៤ | ២៣,៩ | ២៤,៨ | ២៤,៤ | ២៧,៤ | ២៨,៩ |
| រូបិយវត្ថុទូទៅ (M2) | ២០,០ | ២០,០ | ១៦,៥ | ១៧,៧ | ១៨,២ | ១៩,៦ | ២០,៥ |
| រូបិយវត្ថុក្នុងចរាចរណ៍ | ៣,២ | ៣,៥ | ៦,៥ | ១១,៧ | ១៤,១ | ១៤,៦ | ១៣,៥ |
| អតិផរណាប្រចាំឆ្នាំ | ៣,១ | ៣,៣ | ៣,៨ | ៣,៨ | ៥,២ | ៦,៥ | ៥,២ |

## ២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆមាសទី១ នេះ  រូបិយវត្ថុទូទៅមានកំណើន ១៣% បន្តពីកំណើន ១២,៦% និង ៦,៦% ក្នុងឆមាសទី១ និងឆមាសទី២ រៀងគ្នាក្នុងឆ្នាំ២០១០ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅនេះឆ្លុះបញ្ចាំងពីកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន ១.៤០២ ពាន់លានរៀល (៨,៤%) និងទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន ១.១២៨,៨ ពាន់លានរៀល (៤០,៦%) ។ កំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារនេះ ជាចម្បងគឺបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាចំនួន ១.១៨២,៤ ពាន់លានរៀល (៧,៩%) ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជនិងធនាគារឯកទេសកើនឡើងតែចំនួន ២១៩,៦ ពាន់លានរៀល (១២,៨%) ។ ចំណែកឯការវិវឌ្ឍនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធវិញ គឺបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជន[២] ចំនួន ១.៩៥៩,៤ ពាន់លានរៀល (១៤,៧%) ខណៈដែលឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលថយចុះ ចំនួន ៥៧,៦ ពាន់លានរៀល (២,៧%) ហើយដើមទុននិងទុនបម្រុងរបស់ប្រព័ន្ធធនាគារកើនឡើងចំនួន ៨៣៣,៦ ពាន់លានរៀល (៩,៦%) ។ នៅក្នុងកំណើនឥណទានចំពោះវិស័យឯកជនសរុប  វិស័យដែលរួមចំណែកធំជាងគេមាន  ឥណទានចំពោះវិស័យជួញដូរដុំនិងរាយ ៣៥% សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ ១០%  កម្មន្តសាល ៩% សណ្ឋាគារនិងភោជនីយដ្ឋាន ៩% កសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ៧% សំណង់ ៧% អចលនៈទ្រព្យ ៥%  ការឲ្យខ្ចីជាបុគ្គល ៥% ការឲ្យខ្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន ៤% និងផ្សេងទៀត ៩% ។

### ២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន៥៧១,៦ពាន់លានរៀល(១២,១%) ពោលគឺ ថយចុះពី -៤.៧៣៧,៦ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១០ មក -៥.៣០៩,១ ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០១១ បន្ទាប់ពីបានកើនឡើងចំនួន ១៤៤,៤ ពាន់លានរៀល (៣%) ក្នុងឆមាសទី២ ឆ្នាំ២០១០ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធបណ្តាលមកពីការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធចំនួន ៤៤៤,៩ ពាន់លានរៀល (១៧,៧%) ឥណទេយ្យសុទ្ធពីបណ្តាធនាគារពាណិជ្ជចំនួន ៦៥,៣ ពាន់លានរៀល (១៤,៩%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៦១,៤ ពាន់លានរៀល (៣,៤%) ។

---

(២) ឥណទានដុល=ឥណទានសរុប+ការប្រាក់បង្គរ

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា
## ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១

## ទ្រព្យសកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០ | ចំនួនទឹកប្រាក់ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ |
|---|---|---|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ៦១៥.៣៥៨ | ១.០៣៤.៣០០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅស្ថាប័នហិរញ្ញវត្ថុនិងធនាគារបរទេស | ៩.១៨៣.៥២៨ | ៩.៣៨៧.៧៥៨ |
| រូបិយវត្ថុជាតិនៅ IMF | ៥៥៦.២៦២ | ៥៧០.៧៣៩ |
| ឲ្យខ្ចី និងបុរេប្រទានៈ | | |
| - ចំពោះធនាគារពាណិជ្ជ | ៣០.៦៧២ | ៣៥.២០៧ |
| - ចំពោះរាជរដ្ឋាភិបាល | ២៧០.២៤៤ | ២៧០.២៤៤ |
| SDR Holding | ៤២៧.៣១៥ | ៤៥០.២២២ |
| វិនិយោគលើមូលបត្រ | ៣.២៤០.៧៤៤ | ៣.៨២២.២០៦ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ២.២១៩.៨៧២ | ២.៤៩០.៥៧៧ |
| អចលនទ្រព្យ | ៧៤៦.២៩៤ | ៧៥១.៣០៥ |
| ទ្រព្យសកម្មផ្សេងៗ | ២២.៣៥៨១ | ២២.៨៣២ |
| **សរុប** | **១៧.៣១២.៩៧៣** | **១៨.៨៣៨.៤២៣** |

## ទ្រព្យអកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១០ | ចំនួនទឹកប្រាក់ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ |
|---|---|---|
| រូបិយវត្ថុបោះផ្សាយ | ៣.៥២៣.៧៣៩ | ៤.០៧៣.៣១១ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ៧.៤១៥.១០៥ | ៧.៧៥០.០៩០ |
| បំណុលចំពោះមូលនិធិអន្តរជាតិ | ១.០៨៤.៤១១ | ១.១២៧.១៨៩ |
| ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល | ២.០៥២.៨៤៩ | ២.១១៣.៤០៣ |
| រំលោះបង្គរទុក | ១៦២.៩៨៦ | ១៧៦.០២៤ |
| សំវិធានធន | ២៦៤.៤២៦ | ២៦៤.៦០៧ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ២.៧៤៨.១៩៨ | ៣.២១៦.២៩៩ |
| លទ្ធផលជាមូលដ្ឋាន (ប្រាក់ចំណេញឆ្នាំមិនទាន់បែងចែក) | -៣៥.៥៥៨ | -១.៣៣៥ |
| ទ្រព្យអកម្មផ្សេងៗ | ៦.១៨៦ | ១១៧.៨៣៥ |
| **សរុប** | **១៧.៣១២.៩៧៣** | **១៨.៨៣៨.៤២៣** |

ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលជារួម ឆ្លុះបញ្ចាំងនូវការកើនឡើងនៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ចំនួន ៦១,៤ ពាន់លានរៀល (៣%) ខណៈដែលឥណទានចំពោះរាជរដ្ឋាភិបាលមិនមានការប្រែប្រួល ។

ក្នុងអំឡុងឆមាសទី១ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ១.១៨២,៤ ពាន់លានរៀល (៧,៩%) ។ ការវិវត្តនេះ បណ្តាលមកពីកំណើននៃទ្រព្យសកម្មបរទេសចំនួន ១.២០៦,៥ ពាន់លានរៀល (៧,៨%) ខណៈដែលទ្រព្យអកម្មបរទេសកើនឡើងចំនួន ២៤ ពាន់លានរៀល (៥,៦%) ។

### ២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជ និងធនាគារឯកទេសបានកើនឡើងចំនួន ៣.៥៦០,៤ ពាន់លានរៀល (១៣,៥%) ខណៈដែលទ្រព្យអកម្មក្នុងរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ២.២៣៧,៨ ពាន់លានរៀល (១៣,៧%) ឆ្លុះបញ្ចាំងឲ្យឃើញនូវកំណើនសាច់ប្រាក់ងាយស្រួល ដែលជាកត្តាសំខាន់មួយគាំទ្រដល់សកម្មភាពឥណទានរបស់ធនាគារ ហើយរួមចំណែកដល់ការសម្រួលការវិនិយោគនៅក្នុងសេដ្ឋកិច្ច ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន១.៥៩៥,១ពាន់លានរៀល(២២,២%) ។ បម្រែបម្រួលនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃខ្ទង់ឥណទានចំពោះវិស័យឯកជនចំនួន ១.៩៥៩,៤ ពាន់លានរៀល (១៤,៧%) រួមជាមួយនឹងការកើនឡើងនៃខ្ទង់ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៣,៧ ពាន់លានរៀល (១,១%) ខណៈដែលទ្រព្យសកម្មផ្សេងៗសុទ្ធបានបានថយចុះចំនួន ៣៥៦,៣ ពាន់លានរៀល (៦,១%) ។ ការថយចុះនៃទ្រព្យសកម្មផ្សេងៗសុទ្ធជាលទ្ធផលនៃការកើនឡើងនៃទ្រព្យអកម្មផ្សេងៗចំនួន ៧៤៤ ពាន់លានរៀល (៩,៤%) ខណៈដែលទ្រព្យសកម្មផ្សេងៗកើនឡើងចំនួនតែ ៣៨៧,៧ ពាន់លានរៀល (១៨,៦%) ។ ទន្ទឹមនេះដែរ ប្រាក់បម្រុងរបស់បណ្តាធនាគារពាណិជ្ជដែលរួមមាន ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា សាច់ប្រាក់ក្នុងបេឡាបានកើនឡើងចំនួន ៤២៣,១ ពាន់លានរៀល (៥,៧%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជ បានកើនឡើងចំនួន ២១៩,៦ ពាន់លានរៀល (១២,៨%) ពោលគឺកើនពី ១.៧១៥,៥ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១០ ទៅ ១.៩៣៥ ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០១១ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន ៧៩០,៤ ពាន់លានរៀល (២២,៥%) ខណៈដែលទ្រព្យអកម្មបរទេសកើនចំនួន ៥៧០,៨ ពាន់លានរៀល (៣១,៨%) ។

ទ្រព្យអកម្មក្នុងស្រុកក្នុងរូបភាពជាប្រាក់បញ្ញើសរុប មានកំណើនចំនួន ២.២៣៧,៨ ពាន់លានរៀល (១៣,៧%) ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណកើនចំនួន ២.១៩០,១ ពាន់លានរៀល (១៣,៨%) ខណៈដែលប្រាក់បញ្ញើជារៀលកើនឡើងចំនួន ៤៧,៨ ពាន់លានរៀល (៩,៥%) ។

### ២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើនខ្ពស់ជាង ៦% នៅឆ្នាំ២០១១ ហើយអត្រាអតិផរណាឆ្នាំលើឆ្នាំ មានកម្រិតមួយខ្ទង់ ខណៈដែលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារមានស្ថិរភាពជាបង្គួរ ។ ធនាគារជាតិនៃកម្ពុជា បានសម្រេចបន្តរក្សាអត្រាទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណក្នុងកម្រិត ១២% និងអត្រាទុនបម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាក្នុងកម្រិត ៨% ។

ដោយពិនិត្យលើចលនាអត្រាការប្រាក់កម្ចីនិងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជបានបង្ហាញឱ្យឃើញថា ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ អត្រាការប្រាក់បញ្ញើរយៈពេល ៦ខែ ដែលវាស់ដោយកម្រិតមធ្យម ថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារ មាននិន្នាការថយចុះបន្តិច ចាប់តាំងពីដើមឆ្នាំមក ។ អត្រាការប្រាក់បញ្ញើជារៀល និងជាដុល្លារអាមេរិក បានថយចុះចំនួន ០,០៦% ពោលគឺអត្រាការប្រាក់បញ្ញើជារៀលបានថយពី ៥,៤៩% ក្នុងខែធ្នូ ឆ្នាំ២០១០ ដល់ ៥,៤៣% នាខែមិថុនា ឆ្នាំ២០១១ និងអត្រាការប្រាក់បញ្ញើជាដុល្លារបានថយចុះពី ៣,៤៨% នាខែធ្នូ ឆ្នាំ២០១០ មក ៣,៤២% នាខែមិថុនា ឆ្នាំ ២០១១ ។

ទន្ទឹមនឹងនោះ អត្រាការប្រាក់កម្ចីជារៀល និងជាដុល្លារ ដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល ៦ខែ បានថយចុះពី ២២,០៤% និង ១៨,៩៦% នាខែធ្នូ ឆ្នាំ២០១០ មក ២១,៣៤% និង ១៧,៣៦% នាខែមិថុនា ឆ្នាំ២០១១ រៀងគ្នា ។

ក្រាហ្វស្ថិតិ ១០: **អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើ**
(**អត្រាមធ្យម ៦ ខែ**)




ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១១ នេះ គម្លាតអត្រាការប្រាក់ជារៀល បានថយចុះពី ១៦,៥៥% នាខែធ្នូ ឆ្នាំ២០១០ មក ១៥,៩១% នៅខែមិថុនា ឆ្នាំ២០១១ ។ ចំណែកឯគម្លាតអត្រាការប្រាក់ជាដុល្លារ បានថយចុះពី ១៥,៦៦% នាខែធ្នូ ឆ្នាំ២០១០ មក ១៣,៩៤% នៅខែមិថុនា ឆ្នាំ២០១១ ។ ទំហំនៃគម្លាតនេះបង្ហាញពីការថយចុះបន្តិចនៃចំណាយប្រតិបត្តិការរបស់ប្រព័ន្ធធនាគារ ។

## តារាងអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ (អត្រាមធ្យម ៦ខែ - ជាភាគរយ)

| | មករា ២០១០ | កម្ភៈ ២០១០ | មីនា ២០១០ | មេសា ២០១០ | ឧសភា ២០១០ | មិថុនា ២០១០ | ធ្នូ ២០១០ | មករា ២០១១ | កម្ភៈ ២០១១ | មីនា ២០១១ | មេសា ២០១១ | ឧសភា ២០១១ | មិថុនា ២០១១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៥,១៤ | ៥,១២ | ៥,១៣ | ៥,៤៧ | ៥,៤៨ | ៥,៥០ | ៥,៤៩ | ៥,៤៩ | ៥,៤៩ | ៥,៤៣ | ៥,៤៣ | ៥,៤៣ | ៥,៤២ |
| អត្រាការប្រាក់កម្ចីជារៀល | ២២,៧០ | ២២,៧០ | ២២,៦៨ | ២២,៦៥ | ២២,៤២ | ២២,៣៩ | ២២,០៤ | ១៧,៤៥ | ១៧,៤៥ | ២១,៤៤ | ២១,៣៤ | ២១,៤៤ | ១៤,៨០ |
| គម្លាត | ១៧,៥៦ | ១៧,៥៨ | ១៧,៥៥ | ១៧,១៨ | ១៦,៩៤ | ១៦,៨៩ | ១៦,៥៥ | ១២,៩៦ | ១២,៩៦ | ១៦,០១ | ១៥,៩១ | ១៦,០១ | ៩,៣៨ |
| | | | | | | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៤,១៤ | ៤,១៤ | ៤,០៧ | ៤,០១ | ៣,៨៥ | ៣,៨៦ | ៣,៤៨ | ៣,៤៧ | ៣,៤០ | ៣,៤៣ | ៣,៤២ | ៣,៤២ | ៣,៤៤ |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៧,២១ | ១៧,២២ | ១៧,២៦ | ១៧,១៧ | ១៧,១៧ | ១៧,១៣ | ១៩,១៤ | ១៥,៤០ | ១៥,២៣ | ១៦,៦៩ | ១៧,៣៦ | ១៨,៨១ | ១៥,៣៧ |
| គម្លាត | ១៣,០៧ | ១៣,០៨ | ១៣,១៩ | ១៣,១៦ | ១៣,១២ | ១៣,២៧ | ១៥,៦៦ | ១១,៩៣ | ១១,៨៣ | ១៣,២៦ | ១៣,៩៤ | ១៤,៩៩ | ១១,៩៣ |

## ៣- ជញ្ជីងទូទាត់

ដូចបណ្តាប្រទេសទាំងអស់ក្នុងពិភពលោកផងដែរ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងស្ថានភាពក្រោយវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ទន្ទឹមនេះដែរ សេដ្ឋកិច្ចពិភពលោកបានចាប់ផ្តើមងើបឡើងវិញ ដែលធ្វើឲ្យប្រតិបត្តិការជញ្ជីងទូទាត់ប្រទេសកម្ពុជា មានភាពប្រសើរឡើងចាប់ពីឆមាសទី១ ឆ្នាំ២០១០រហូតដល់ឆមាសទី១ ឆ្នាំ២០១១។ យោងតាមការប៉ាន់ស្មានជំហានដំបូង សមតុល្យរួមនៃជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា មានអតិរេកចំនួន ១១០,៣ លានដុល្លារអាមេរិក ក្នុងឆមាសទី១ ឆ្នាំ២០១១ បានកើនឡើង ៤០,១ លានដុល្លារអាមេរិក (៥៧,១%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០១០ ។ ការកើនឡើងនេះ បណ្តាលមកពីកំណើននៃបង្វែរផ្លូវការប្រមាណ ១១% ខណៈដែលឱនភាពគណនីចរន្តបានកើនឡើង ១០% តែប៉ុណ្ណោះ ។ ក្នុងអំឡុងពេលនេះដែរ ផលធៀបនៃគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងផលិតផលក្នុងស្រុកសរុបមានកម្រិត ១២,៤% ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

គណនីចរន្ត មានឱនភាពប្រមាណ ៧៧៥,៨ លានដុល្លារអាមេរិក បានកើនឡើង ៧០,៦ លានដុល្លារអាមេរិក (១០%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០១០ ។ មូលហេតុចម្បងនៃការកើនឡើងនេះ គឺការកើនឡើងឱនភាពជញ្ជីងពាណិជ្ជកម្មប្រមាណ ៥១,៧ លានដុល្លារអាមេរិក (៥,៨%) និងការកើនឡើងឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ៦៩,៩ លានដុល្លារអាមេរិក (២៦,៦%) ដែលបានផាត់ទាត់ដោយ ការកើនឡើងអតិរេកគណនីសេវាសុទ្ធប្រមាណ ២៦ លានដុល្លារអាមេរិក (៧,៥%) និងការកើនឡើងអតិរេកគណនីបង្វែរឯកជនប្រមាណ ២៥,១ លានដុល្លារអាមេរិក (២៤,៧%) ។

តម្លៃនៃការនាំចេញផលិតផលក្នុងស្រុកមានប្រមាណ ២.៥៥៨,៩ លានដុល្លារអាមេរិក បានកើនឡើង ១៦២,១ លានដុល្លារអាមេរិក (៦,៨%) ធៀបនឹងឆមាសទី១ នៃឆ្នាំកន្លងទៅ ។ កត្តារួមចំណែកយ៉ាងសំខាន់ក្នុងការកើនឡើងតម្លៃនាំចេញផលិតផលក្នុងស្រុកនេះ គឺការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌដែលបានកើនឡើងប្រមាណ ៣៨៤,២ លានដុល្លារអាមេរិក (២៨,៥%) ។ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌរបស់ប្រទេសកម្ពុជា បានបន្តកើនឡើងជាលំដាប់ ពោលគឺមានប្រមាណ ១.៧៣២,២



លានដុល្លារអាមេរិក ក្នុងឆមាសទី១ ឆ្នាំ២០១១ ធៀបនឹង ១.៣៤៨ លានដុល្លារអាមេរិក ក្នុងឆមាសទី១ ឆ្នាំ ២០១០ ដែលការនាំចេញនេះមានចំនួន ១.១៤២,៨ លានដុល្លារអាមេរិក ក្នុងឆមាសដូចគ្នានៃឆ្នាំ២០០៩ ។

តម្លៃនៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមានប្រមាណ ៣.៥៣០ លានដុល្លារអាមេរិក បានកើនឡើង ២១៨,៩ លានដុល្លារអាមេរិក (៦,៦%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។ កត្តាដែលបណ្ដាលឱ្យមានការកើនឡើងនេះ គឺការកើនឡើងតម្លៃនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ប្រមាណ ៤៨,៤ លានដុល្លារអាមេរិក (៧,៦%) ការកើនឡើងតម្លៃនាំចូលប្រេងឥន្ធនៈប្រមាណ ៩៣,៦ លានដុល្លារអាមេរិក (៧,៥%) និងការកើនឡើងតម្លៃនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងទៀតប្រមាណ ៧៦,៧ លានដុល្លារអាមេរិក (៥,៤%) ។ ការកើនឡើងតម្លៃនាំចូលទំនិញទាំងនេះ ជាចម្បងបណ្ដាលមកពីកំណើននៃថ្លៃមុខទំនិញនីមួយៗ ជាពិសេស ថ្លៃប្រេងក្នុងមួយឯកតាបានកើនប្រមាណ ២៥% ធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០១០ ។

ក្នុងអំឡុងពេលដូចគ្នានេះ អតិរេកគណនីសេវាសុទ្ធមានប្រមាណ ៣៧១,៣ លានដុល្លារអាមេរិក បានកើនឡើង ២៦ លានដុល្លារអាមេរិក (៧,៥%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១០ ។ អតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវា បន្ទាប់ពីផាត់ទាត់ចំណាយលើផ្នែកសេវាដែលផ្ដល់ដោយអនិវាសជន ។ ការកើនឡើងចំណូលពីសេវាទេសចរណ៍ប្រមាណ ៧០,១ លានដុល្លារអាមេរិក (១១,៣%) និងការកើនឡើងចំណូលពីសេវាដឹកជញ្ជូនតាមផ្លូវអាកាសប្រមាណ ៧,៩ លានដុល្លារអាមេរិក (៧,៣%) បានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើនប្រាក់ចំណូលពីផ្នែកសេវានេះ ។ ដោយសារបរិស្ថានសង្គម ការធ្វើពិពិធកម្ម និងការផ្ដល់សេវាឲ្យភ្ញៀវទេសចរបរទេស ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ចំណូលពីផ្នែកសេវាទេសចរណ៍ត្រូវបានរំពឹងថាកើនឡើង ១០% ធៀបនឹង ៦ខែ ដើមឆ្នាំ២០១០ ។ គណនីប្រាក់ចំណូលសុទ្ធ មានឱនភាពប្រមាណ ៣៣២,៩ លានដុល្លារអាមេរិក បានកើនឡើង ៦៩,៩ លានដុល្លារអាមេរិក (២៦,៦%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១០ ។ ការកើនឡើងឱនភាពនេះ បណ្ដាលមកពីការកើនឡើងការផ្ទេរប្រាក់ចេញទៅឱ្យអនិវាសជន ៧២ លានដុល្លារអាមេរិក (២៥%) ។ គណនីបង្វែរឯកជនសុទ្ធមានអតិរេកប្រមាណ ១២៦,៦ លានដុល្លារអាមេរិក បានកើនឡើង ២៥,១ លានដុល្លារអាមេរិក (២៤,៧%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ដោយសារការកើនឡើងការផ្ទេរប្រាក់មកពីក្រៅប្រទេសរបស់ជនជាតិកម្ពុជា ។

### ៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ

លំហូរបង្វែរផ្លូវការសុទ្ធក្រោមរូបភាពជាហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងមានប្រមាណ ៤៣០ លានដុល្លារអាមេរិក បានកើនឡើង ៤២,៥ លានដុល្លារអាមេរិក (១១%) ធៀបនឹងឆមាសទី១ ឆ្នាំ២០១០ ។ ក្នុងអំឡុងពេលនេះដែរ លំហូរជាជំនួយប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) មានប្រមាណ ១៣៤,៧ លានដុល្លារអាមេរិក បានថយចុះ ២៣,៥% ធៀបនឹងឆមាសដូចគ្នានៃឆ្នាំមុន ។ ចំណែកលំហូរវិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួនប្រមាណ ៣៧៥ លានដុល្លារអាមេរិក បានកើនឡើង ៧៦,៩ លានដុល្លារអាមេរិក (២៥,៨%) ដែលបង្ហាញពីបរិយាកាសវិនិយោគបរទេសមានភាពប្រសើរឡើងវិញ ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។

ក្រាហ្វិកទី ១២ : ជញ្ជីងទូទាត់កម្ពុជា




ក្នុងអំឡុងពេល ៦ខែ ដើមឆ្នាំ២០១១ នេះ លំហូរចូលនៃគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុ បានបង្ហាញពីកំណើនរូបិយប័ណ្ណរបស់ប្រទេសកម្ពុជាដែលផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ និងផាត់ទាត់ឱនភាពគណនីចរន្ត ។ លទ្ធផលនេះ បង្ហាញឲ្យឃើញថា សមតុល្យរួមនៃប្រតិបត្តិការជញ្ជីងទូទាត់ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ មានអតិរេក ១១០,៣ លានដុល្លារអាមេរិក ។ គិតដល់ចុងខែមិថុនា ទុនបម្រុងអន្តរជាតិដុល អាចធានាដល់ការទូទាត់ទំនិញនាំចូលបានប្រមាណ ៤ខែ ។

## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជា វិនិយោគទុនបម្រុងអន្តរជាតិក្រោមរូបភាពជាអូវើណាយ (Overnight) ប័ណ្ណរតនាគារអាមេរិក (US Treasury Bills) ឧបករណ៍ហិរញ្ញវត្ថុរយៈកាលមធ្យម (MTI) និងប្រាក់បញ្ញើរយៈកាលខ្លីជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារនិងក្រេឌីតរ៉េទីង (Credit Rating) ខ្ពស់ ។

### ៤.២. គោលការណ៍វិនិយោគទុនបម្រុងអន្តរជាតិ

តាមគោលការណ៍កំណត់ដោយគណៈកម្មការវិនិយោគ មន្ត្រីគ្រប់គ្រងទុនបម្រុងអន្តរជាតិត្រូវចាត់ចែងការវិនិយោគដោយប្រុងប្រយ័ត្ន ដោយប្រកាន់យកលំដាប់អាទិភាព ទី១-សុវត្ថិភាព ទី២-សាច់ប្រាក់ងាយស្រួល និងទី៣-ប្រាក់ចំណូល ។ ការកំណត់តណប្រតិទាន ការជ្រើសរើសដៃគូ និងការកំណត់ឧបករណ៍វិនិយោគក៏ត្រូវធ្វើដោយប្រុងប្រយ័ត្នយោងតាមសេចក្តីណែនាំការវិនិយោគដែលអនុម័តដោយគណៈកម្មការវិនិយោគ ។

### ៤.៣. សភាពការណ៍ទីផ្សារវិនិយោគទុនបម្រុងអន្តរជាតិ

សេដ្ឋកិច្ចសហរដ្ឋអាមេរិកមិនទាន់មានភាពប្រសើរឡើងវិញទាំងស្រុងនៅឡើយទេ ដោយសារអត្រាអត់ការងារធ្វើនៅមានកម្រិតខ្ពស់ ទីផ្សារលំនៅដ្ឋានមិនទាន់រីកចម្រើនជាក់លាក់ ហើយតម្លៃប្រេងនៅបន្តឡើងថ្លៃជាបន្តបន្ទាប់ ដែលជាកត្តាជំរុញឲ្យអត្រាអតិផរណាអាមេរិកកើនឡើងខ្ពស់ ។ បញ្ហាទាំងនេះបានបង្កជាក្តីបារម្ភដ៏ចម្បងចំពោះធនាគារកណ្តាលសហរដ្ឋអាមេរិក (FED) ក្នុងការកំណត់គោលនយោបាយរូបិយវត្ថុឲ្យ

បានសមស្រប និងមានប្រសិទ្ធភាព ។ FED បានរក្សាអត្រាការប្រាក់គោលប្រាក់ដុល្លារអាមេរិកនៅត្រឹមកម្រិតទាបបំផុត ០,២៥% និងមិនមានការរំពឹងថា អត្រាការប្រាក់គោល នេះអាចនឹងត្រូវដំឡើងនៅក្នុងឆមាសទី២ ឆ្នាំ២០១១ ខាងមុខនេះទេ ។ ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅតំបន់អឺរ៉ុប ហាក់មានភាពល្អប្រសើរបន្តិច បើធៀបនឹងឆមាសទី២ ឆ្នាំ២០១០ ទោះបីជាវិបត្តិបំណុលមិនទាន់អាចត្រូវបានដោះស្រាយដោយជោគជ័យទាំងស្រុងក៏ដោយ ។ អត្រាការប្រាក់គោលប្រាក់អឺរ៉ូក៏ត្រូវបានបង្កើនមួយលើកចំនួន ២៥ ពិន្ទុ គឺពី ១% ទៅ ១,២៥% ដើម្បីទប់ទល់នឹងការកើនឡើងខ្ពស់នៃអត្រាអតិផរណា ហើយមានការរំពឹងទុកថា អត្រាការប្រាក់គោលនេះអាចនឹងត្រូវបានបង្កើនទៀតនៅក្នុងឆមាសទី២ ឆ្នាំ២០១១ ។ ទន្ទឹមនេះ នៅប្រទេសអង់គ្លេស អត្រាអតិផរណាបានកើនឡើងខ្ពស់នៅក្នុងឆមាសទី១ ឆ្នាំ២០១១ ដែលជាក្តីកង្វល់ដ៏ចម្បងរបស់ប្រទេសអង់គ្លេស ប៉ុន្តែធនាគារកណ្តាលអង់គ្លេស មិនបានបង្ហាញជំហរជាក់លាក់របស់ខ្លួនក្នុងការបង្កើនអត្រាការប្រាក់គោលនៃប្រាក់ផោនស្ទែរលីងទេ គឺនៅរក្សាត្រឹម ០,៥% ដដែលនៅក្នុងឆមាសទី២ ។ ផ្ទុយទៅវិញ ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសអូស្ត្រាលីនៅតែមានភាពរឹងមាំ ដោយសារសន្ទុះរីកចម្រើននៃឧស្សាហកម្មរ៉ែ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រទេសចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់ប្រទេសអូស្ត្រាលី ។ នៅក្នុងឆមាសនេះ ធនាគារកណ្តាលអូស្ត្រាលីមិនមានដំឡើងអត្រាការប្រាក់គោលប្រាក់ដុល្លារអូស្ត្រាលីទេ គឺនៅរក្សាត្រឹម ៤,៧៥% ដដែល ប៉ុន្តែអាចនឹងត្រូវបានបង្កើននៅក្នុងឆមាសទី២ ឆ្នាំ២០១១ ដើម្បីទប់ទល់នឹងការកើនឡើងខ្ពស់នៃអត្រាអតិផរណាបច្ចុប្បន្ន ។

### ៥- សម្ព័ន្ធការងារមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គិតត្រឹមឆមាសទី១ ឆ្នាំ២០១១ ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ២៩ ធនាគារឯកទេសចំនួន ៦ ការិយាល័យតំណាងធនាគារបរទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២៧ ក្នុងនោះ គ្រឹះស្ថានចំនួន ៧ ទទួលប្រាក់បញ្ញើពីសាធារណជន និងប្រតិបត្តិករឥណទានជនបទចំនួន ២៨ ។ ក្រៅពីនេះ មានប្រតិបត្តិករផ្តល់សេវាហិរញ្ញវត្ថុមានប្រមាណ ៦០ ។ ចំនួនប្រតិបត្តិករ និងមូលដ្ឋានអតិថិជន របស់គ្រឹះស្ថានធនាគារ មានការរីកដុះដាលពាសពេញក្នុងផ្ទៃប្រទេស ។ ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកទទួលឥណទានកើនឡើងដល់ ១.១៧៣.៤៤៦ នាក់ និង ២៨៥.៨៥៥ នាក់ ។ បណ្តាញសាខារបស់គ្រឹះស្ថានធនាគារកើនឡើងខ្លាំង ជាពិសេសនៅក្នុងអំឡុងឆ្នាំចុងក្រោយនេះ ។ មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យានៅក្នុងវិស័យ មានការរីកលូតលាស់ជាលំដាប់ ដូចជាមាន ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ផលិតផល និងសេវាកម្មធនាគារផ្សេងៗទៀត ។ ចំពោះការអនុវត្តបទបញ្ញាប្រុងប្រយ័ត្ន មានភាពប្រសើរឡើងផងដែរ ។ នៅដំណាច់ឆមាសទី១ ឆ្នាំ២០១១នេះ អនុបាតសាធនភាព ជាមធ្យមមានប្រមាណ ៣១% ខ្ពស់ជាងកម្រិតអប្បបរមា ១៥% ចំណែកអនុបាតសាច់ប្រាក់ងាយស្រួលមាន ចំនួន ៩២% លើសពីកម្រិតតម្រូវការ ៥០% ។ ឥណទានមិនដំណើរការ ងើបឡើងបន្តិចមកត្រឹម ៣,១៥% ធៀបនឹងខែធ្នូ ឆ្នាំ២០១០ មានចំនួន ៣,០៥%។ ជារួម គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអនុវត្តបានល្អប្រសើរនូវបទបញ្ញាប្រុងប្រយ័ត្នដែលដាក់ចេញដោយអាជ្ញាធរអាណាព្យាបាល ។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ និងតាមដានប្រតិបត្តិការនៅក្នុងប្រព័ន្ធធនាគារ ការគ្រប់គ្រងទិន្នន័យ និងការអភិវឌ្ឍការិយាល័យឥណទាន ។ ការតាមដានលើប្រតិបត្តិការ

នៅក្នុងប្រព័ន្ធធនាគារទាំងមូល ត្រូវបានពង្រឹងបន្ថែមទៀត ដោយផ្តោតលើប្រភេទប្រតិបត្តិការរបស់ធនាគារ និងពិនិត្យលើប្រតិបត្តិករដើម្បីជំរុញឲ្យមានការប្រកួតប្រជែងបន្ថែមទៀត ។ ការតាមដាននេះធ្វើឡើងតាមរយៈ ការពិនិត្យលើហានិភ័យ និងការអនុវត្តបទបញ្ញាប្រុងប្រយ័ត្នរបស់គ្រឹះស្ថានធនាគារជារួម ។ ជាមួយ គ្នានេះ យន្តការ និងសូចនាករមួយចំនួនទៀត ត្រូវបានរៀបចំឡើងដើម្បីពង្រឹងការតាមដាន ដូចជាការសាកល្បង (Stress-Test) សូចនាករស្តីពីស្ថិរភាពហិរញ្ញវត្ថុ (Financial Soundness Indicators) និងព័ត៌មានស្តីពី ហានិភ័យអន្តរធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ជាពិសេស នៅក្នុងដំណាក់កាលដែលប្រទេសកម្ពុជា ត្រៀមបង្កើតទីផ្សារហ៊ុន ។ ចំពោះការគ្រប់គ្រងទិន្នន័យត្រូវបានអភិវឌ្ឍបន្ថែមទៀតតាមរយៈការកែសម្រួលគំរូ របាយការណ៍ត្រួតពិនិត្យ ដើម្បីកាត់បន្ថយបន្ទុកក្នុងការរាយការណ៍ និងការចាប់យកព័ត៌មានផ្សេងទៀតដែល ចាំបាច់ និងកែលំអប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យបន្ថែមទៀត ។

ធនាគារជាតិនៃកម្ពុជាបានរៀបចំ និងដាក់ចេញឲ្យប្រើប្រាស់ប្រកាសស្តីពីប្រព័ន្ធចែករំលែកព័ត៌មាន ឥណទាននៅកម្ពុជា ដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយការជឿទុកចិត្ត ការប្រកួតប្រជែង ការទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ ។ បច្ចុប្បន្នេះ ការិយាល័យក្រេឌីតប៊ុយរ៉ូកម្ពុជា (Credit Bureau Cambodia) បានដំណើរការសាកល្បងប្រមូលទិន្នន័យ ១០% នៃសម្ពាធឥណទានរបស់សាមីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងកំពុងដំណើរការរៀបចំសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ។

## ៥.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ការដាក់ឲ្យអនុវត្តប្រកាសពីរពាក់ព័ន្ធនឹងដើមទុនរបស់គ្រឹះស្ថានធនាគារ បានតម្រូវឲ្យបង្កើនដើមទុន តាមលក្ខខណ្ឌរបស់ធនាគារជាតិនៃកម្ពុជា និងតម្រូវឲ្យបែងចែកដើមទុនជាពីរប្រភេទធំៗស្របតាមការអនុវត្ត ជាអន្តរជាតិ គឺដើមទុនស្នូល ឬ ដើមទុនថ្នាក់ទីមួយ និងដើមទុនបន្ទាប់បន្សំ ឬ ដើមទុនថ្នាក់ទីពីរ ។ មូលដ្ឋាន នៃដើមទុនរបស់គ្រឹះស្ថានធនាគារកាន់តែមានភាពរឹងមាំ និងមានធនាគារមួយចំនួនបានស្នើសុំបង្កើនដើមទុន ចុះបញ្ជីបន្ថែមទៀតទោះជាមានដើមទុនគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌក៏ដោយ ។ ទន្ទឹមនឹងនេះ ធនាគារពាណិជ្ជ មួយចំនួនបានសម្រេចប្រែក្លាយខ្លួនជាធនាគារឯកទេសវិញ ។

ការបើកសាខានៅតាមទីប្រជុំជន និងនៅតាមបណ្តាខេត្ត-ក្រុងនានា កាន់តែមានសកម្មភាពផុលផុស ។ ចំនួនសាខាមានការកើនឡើងជាលំដាប់ ។ ដោយឡែក ក្នុងអំឡុងឆមាសទី១ នេះ សាខាថ្មីចំនួន ៥ ត្រូវបាន បើកដំណើរការ ហើយធនាគារមួយចំនួនមានផែនការបើកសាខាចំនួន ៧ បន្ថែមទៀត ។ ក្រៅពីសាខាដែល បានបើកនៅក្នុងប្រទេស មានធនាគារពីរដែលមានសាខានៅក្រៅប្រទេស ក្នុងនោះមានសាខាថ្មីមួយត្រូវបាន បើកក្នុងអំឡុងឆមាសទី១ នេះផងដែរ ។ ដោយមានសុទិដ្ឋិនិយមចំពោះភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា និងដើម្បីសម្រួលដល់ប្រតិបត្តិការកាន់តែឆាប់រហ័ស ធនាគារដែលជាសាខាបរទេសមួយចំនួនបានដាក់ពាក្យ ស្នើសុំ និងមានផែនការស្នើសុំប្រែក្លាយខ្លួនមកជាធនាគារដែលបង្កើតឡើងក្រោមច្បាប់ក្នុងស្រុកវិញ ។

ការវិភាគស្ថានភាពធនាគារ ដោយផ្អែកលើវិធីសាស្ត្រ CAMEL បានបង្ហាញថា ដើមទុនរបស់គ្រឹះស្ថាន ធនាគារមានស្ថានភាពល្អប្រសើរ និងកាន់តែមានភាពរឹងមាំ ចំពោះស្ថានភាពទ្រព្យសកម្មនិងប្រាក់ចំណេញ របស់ធនាគារមានស្ថានភាពមធ្យម ចំណែកឯសាច់ប្រាក់ងាយស្រួលមានស្ថានភាពល្អប្រសើរ ។

**៥.១.២ ការចុះត្រួតពិនិត្យដល់ទីកន្លែង**

យោងតាមផែនការត្រួតពិនិត្យដល់ទីកន្លែងប្រចាំឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាមានគម្រោងចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ២៥ ធនាគារឯកទេសចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំនួន ១៦ និងប្រតិបត្តិករឥណទានជនបទចំនួន ៤ ដោយមានមន្ត្រីចំនួន ២១ រូប កំពុងបម្រើការនិងទទួលភារកិច្ចក្នុងការអនុវត្តផែនការនេះដោយផ្ទាល់ ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ១០ ធនាគារឯកទេសចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១០ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៣) និងប្រតិបត្តិករឥណទានជនបទចំនួន ២ ។ តាមរយៈការត្រួតពិនិត្យខាងលើបានបង្ហាញថា ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមានលក្ខណៈល្អប្រសើរ ។ ប៉ុន្តែគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមួយចំនួនតូចនៅមានបញ្ហាប្រឈមដូចជា ការអនុវត្តផែនការយុទ្ធសាស្ត្រ ការត្រួតពិនិត្យផ្ទៃក្នុង និងការប្រកាន់ខ្ជាប់តាមគោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរ ។ រាល់ចំណុចខ្វះខាតដែលបានរកឃើញទាំងនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អនុសាសន៍ដល់គ្រឹះស្ថានសាមីដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែង ។

**៥.១.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបមានចំនួន ២៧ (ក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនមានចំនួន ៧) ។ សមតុល្យឥណទានសរុបបានផ្តល់មានចំនួនប្រមាណ ២.១២១ ពាន់លានរៀល កើនឡើងប្រមាណចំនួន ១២% ធៀបនឹងដំណាច់ត្រីមាសទី១ ឆ្នាំ២០១១ ដែលបានផ្តល់ជូនអតិថិជនចំនួនប្រមាណ ១.០១៩.៤១១ នាក់ ក្នុងនោះប្រមាណ ៨២% ជាស្ត្រីរស់នៅតាមជនបទ ។ ជាមួយគ្នានេះដែរ ប្រតិបត្តិករឥណទានជនបទមានចំនួន ២៨ និងបានផ្តល់ឥណទានចំនួនប្រមាណ ៣៥,៤៥ ពាន់លានរៀល ។

ការត្រួតពិនិត្យទាំងលើឯកសារនិងដល់ទីកន្លែង បានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តយ៉ាងយកចិត្តទុកដាក់និងដោយប្រុងប្រយ័ត្នក្នុងការតាមដានឥណទាន ទាំងឥណទានដែលបានដាក់ចេញ និងឥណទានដែលមានគម្រោងនឹងដាក់ចេញ ដែលជាលទ្ធផលធ្វើឲ្យគុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងរយៈពេលមួយឆមាសកន្លងមកនេះ មានភាពកាន់តែប្រសើរឡើង ។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០១១ អនុបាតឥណទានមិនដំណើរការមានចំនួន ១,៣% ។

ទន្ទឹមនឹងការរីកចម្រើនផ្នែកសេវាកម្មឥណទាន សេវាកម្មប្រាក់សន្សំក៏កំពុងរីកចម្រើនយ៉ាងឆាប់រហ័សផងដែរ ។ បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនសរុបមានចំនួន ៧ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា អម្រឹត ហត្ថាកសិករ ប្រាសាក់ អង្គរមីក្រូហិរញ្ញវត្ថុ ក្រេឌីត និងវីសិនហ្វាន់ ។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០១១ ប្រាក់សន្សំសរុបប្រមូលដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួនប្រមាណ ២៧៣ ពាន់លានរៀល ។

ទោះជាវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងតែបន្តការរីកចម្រើនលូតលាស់ជាលំដាប់ ក្រោមបរិយាកាសស្ថិរភាពនយោបាយ និងកំណើនទំនុកចិត្តរបស់សាធារណជន ទាំងវិនិយោគិនក្នុងស្រុកនិងអន្តរជាតិក្តី ធនាគារ

ជាតិនៃកម្ពុជានៅតែបន្តព្យាយាមពង្រឹង និងរក្សាស្ថិរភាពនៃដំណើរនៃវិស័យនេះ តាមរយៈការធ្វើបច្ចុប្បន្នកម្ម និងដាក់ចេញនូវបទបញ្ញានានា សំដៅបង្កើតមូលដ្ឋានច្បាស់លាស់សម្រួលដល់ការអនុវត្តប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថាន ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យរបស់ខ្លួន ទាំងការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង ក្នុងគោលបំណងរក្សាតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងការពារផលប្រយោជន៍សាធារណជនជាអាទិភាព ។ ទន្ទឹមនោះ ប្រព័ន្ធព័ត៌មានវិទ្យាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Microfinance Information System) ដែលជាប្រព័ន្ធរាយការណ៍អេឡិចត្រូនិច ត្រូវបានដាក់ឲ្យអនុវត្តសាកល្បងដើម្បីធានាប្រសិទ្ធភាពរបាយការណ៍ក្នុងទម្រង់បទដ្ឋានតែមួយ ។ ធនាគារជាតិនៃកម្ពុជាគ្រោងនឹង តម្រូវឲ្យគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្តប្រព័ន្ធនេះជាផ្លូវការពេញលេញ ក្នុងពេលឆាប់ៗខាងមុខ ។

ធនាគារជាតិនៃកម្ពុជាក៏កំពុងបន្តការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន លើការត្រួតពិនិត្យគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីផ្តល់ជំនួយបច្ចេកទេសក្នុងការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក សំដៅជំរុញគុណភាពប្រព័ន្ធមីក្រូហិរញ្ញវត្ថុទាំងមូល ។

**៥.២.ការងារនីតិកម្ម**

ក្រោយពីបានធ្វើវិសោធនកម្មប្រកាសស្តីពីរចនាសម្ព័ន្ធ និងមុខងារភារកិច្ច របស់នាយកដ្ឋានត្រួតពិនិត្យមកជាអគ្គនាយកដ្ឋានត្រួតពិនិត្យចូលជាធរមានរួចមក ការងារបែងចែកតួនាទី និងភារកិច្ចរបស់មន្ត្រីបុគ្គលិកតាមនាយកដ្ឋាននីមួយៗ បានផ្ទេរភារកិច្ចដោយសហការគ្នាបានល្អ ដើម្បីសម្រេចបានជោគជ័យ និងដំណើរការរលូនទៅមុខ ។

អាស្រ័យទៅនឹងស្ថានភាព នៃការរីកចម្រើននិងការវិវឌ្ឍនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម ច្បាប់ ប្រកាស បទប្បញ្ញត្តិ សារាចរណែនាំមួយចំនួន ដើម្បីធ្វើឲ្យការងារត្រួតពិនិត្យកាន់តែប្រសើរឡើងថែមទៀត និងប្រព័ន្ធធនាគារកាន់តែមានភាពរឹងមាំ និងមានសុវត្ថិភាពសម្រាប់សាធារណជន ។

**៥.៣. ការងារផ្តល់អាជ្ញាប័ណ្ណ និងជម្រះបញ្ជី**

ធនាគារជាតិនៃកម្ពុជាបានចេញលិខិតយល់ព្រមជាគោលការណ៍ជូនគ្រឹះស្ថានធនាគារចំនួន ១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១ ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្ត និងផ្តល់លិខិតអនុញ្ញាតប្តូរប្រាក់ថ្មីរបស់អាជីវករចំនួន ១៥ អាជ្ញាប័ណ្ណប្តូរប្រាក់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ១៤ និងអាជ្ញាប័ណ្ណអ្នកដំណើរការតតិយភាគីចំនួន ៩ ។ ចំពោះការជម្រះបញ្ជី ធនាគារជាតិនៃកម្ពុជាសហការជាមួយស្នងការគណនេយ្យឯករាជ្យ Ernst & Young កំពុងដំណើរការជម្រះបញ្ជីលើធនាគារឯកទេសខេមបូខាឌីវេឡុបមេន ។

## ៦- ការផ្គត់ផ្គង់សេវាកម្មធនាគារកណ្តាល

### ៦.១- សេវាកម្មគ្រប់គ្រងគណនី

បច្ចុប្បន្ននេះ នាយកដ្ឋានប្រតិបត្តិការគ្រប់គ្រងគណនីជារូបិយវត្ថុជាតិនិងជាដុល្លារអាមេរិកមានចំនួន ១.២៥០ គណនី ។ គណនីទាំងនោះជារបស់ស្ថាប័នរដ្ឋ និងអង្គភាពរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

### ៦.១.១- ចំពោះស្ថាប័នរដ្ឋ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធនាគារជាតិនៃកម្ពុជាបានបើកគណនីជូនស្ថាប័នរដ្ឋ និងផ្តល់សេវាទូទាត់មានដូចជា ដកសាច់ប្រាក់ ផ្ទេរប្រាក់ បើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់របស់រតនាគារជាតិ ។

ការបង់ពន្ធដារ និងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាបានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ១.៧៣៨ ពាន់លានរៀល ។

ធនាគារជាតិនៃកម្ពុជា បានទិញប្រាក់ដុល្លារអាមេរិកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៤២,៣៣ លានដុល្លារអាមេរិក និងលក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញចំនួន ៤៩,៥០ លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាក៏បានទិញប្រាក់ដុល្លារអាមេរិកពីអគ្គិសនីកម្ពុជាចំនួន ១០,៥០ លានដុល្លារអាមេរិក និងបានលក់ជូនអគ្គិសនីកម្ពុជាចំនួន ៣០ លានដុល្លារអាមេរិកផងដែរ ។

### ៦.១.២- ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកនៅធនាគារជាតិនៃកម្ពុជា រួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ សមតុល្យសរុបនៃប្រាក់បញ្ញើទាំងនោះមានចំនួន ៩៧៩ ពាន់លានរៀល និង ៣.១៤២ លានដុល្លារអាមេរិក ។

### ៦.២- សេវាកម្មផ្ទេរប្រាក់ក្នុងប្រទេស

+ ការផ្ទេរចូលមកទីស្នាក់ការកណ្តាល
  - -ជាប្រាក់រៀលមានចំនួន ៣២១ ពាន់លានរៀល
  - -ជាប្រាក់ដុល្លារមានចំនួន ២៩១ លានដុល្លារអាមេរិក
+ ការផ្ទេរចេញទៅសាខារាជធានី-ខេត្ត
  - -ជាប្រាក់រៀលមានចំនួន ៦២៧ ពាន់លានរៀល
  - -ជាប្រាក់ដុល្លារមានចំនួន ៥៩ លានដុល្លារអាមេរិក ។

### ៦.៣- សេវាកម្មផាត់ទាត់មូលប្បទានបត្រ

ប្រតិបត្តិការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកត្រូវបានអនុវត្តជារៀងរាល់ថ្ងៃធ្វើការ ។ ការទូទាត់តាមរយៈសភាផាត់ទាត់នេះ បានដំណើរការប្រកបដោយប្រសិទ្ធភាព ។

### ៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀលមានសមាជិកចំនួន ២៨ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ២៥ ធនាគារឯកទេសចំនួន ២ និងធនាគារជាតិនៃកម្ពុជា ។

ការផាត់ទាត់បានដំណើរការចំនួន ១១៥ ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានបត្រចំនួន ១៦.៧០០ សន្លឹក ស្មើនឹង ៨៨០ ពាន់លានរៀល ។ ប្រៀបធៀបនឹងឆមាសទី២ ឆ្នាំ២០១០ ចំនួនមូលប្បទានបត្រមាន

ចំនួនប្រហាក់ប្រហែលគ្នា និងចំនួនប្រាក់បានកើនប្រមាណ ៤ % ។

**៦.៣.២- ការផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិក**

សភាផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ៣៤ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ២៩ ធនាគារឯកទេស ៤ និងធនាគារជាតិនៃកម្ពុជា ។

ការផាត់ទាត់បានដំណើរការចំនួន ១១៥ ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានបត្រចំនួន ២៦៣.៨០០ សន្លឹក ស្មើនឹង ៤.៤១៤ លានដុល្លារអាមេរិក ។ បើប្រៀបធៀបនឹងឆមាសទី២ ឆ្នាំ២០១០ ចំនួនមូលប្បទានបត្របានកើន ២% និងចំនួនប្រាក់បានកើន ១៩% ។

**៦.៤- ការងារឥណទាន**

ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទានចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ និងប្រមូលបំណុលដែលដល់កាលទូទាត់សងដូចខាងក្រោម៖

- សមតុល្យដើមគ្រា ៣០,៥២ ពាន់លានរៀល
- ឥណទានដែលបានផ្តល់ ៥២,០២ ពាន់លានរៀល
- ឥណទានដែលបានទូទាត់សង ៣៨,៥២ ពាន់លានរៀល
- សមតុល្យចុងគ្រា ៤៧,០២ ពាន់លានរៀល ។

**៦.៥- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល**

**ក- ហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលជប៉ុន**

**ក.១- ហិរញ្ញប្បទានឥតសំណងជាគម្រោង**

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងគម្រោងបី បន្ថែមទៀត ១)-គម្រោងការពារទឹកជំនន់ក្នុងទីក្រុងភ្នំពេញជំហានទី៣ មានទឹកប្រាក់ចំនួន ៣.៧០០ លានយ៉េន ២)-គម្រោងបំពាក់ឧបករណ៍សម្រាប់សកម្មភាពបោសសម្អាតមីនជំហានទី៦ មានទឹកប្រាក់ចំនួន ១.២៩៨ លានយ៉េន និង ៣)-គម្រោងជួសជុល និងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តនានា មានទឹកប្រាក់ ចំនួន ២.៧៦០ លានយ៉េន ។ ដើម្បីសម្រួលដល់ការអនុវត្តគម្រោងខាងលើនេះ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខា Banking Arrangement ជាមួយធនាគារ The Bank of Tokyo-Mitsubishi UFJ, Ltd., សម្រាប់ធ្វើការទូទាត់ ប៉ុន្តែហិរញ្ញប្បទានសម្រាប់គម្រោងទាំងបីខាងលើនេះពុំទាន់ប្រើប្រាស់នៅឡើយទេ ។

ចំពោះគម្រោងដែលបានផ្តល់នាឆ្នាំកន្លងមក និងកំពុងអនុវត្តមិនទាន់ចប់មានដូចខាងក្រោម៖

១- គម្រោងជួសជុលទ្វារទឹករលាំងជ្រៃខេត្តកំពង់ស្ពឺ មានទឹកប្រាក់ចំនួន ៨១៩ លានយ៉េន (ពុំទាន់បានប្រើប្រាស់)

២- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស SCHOLARSHIP0811 មានទឹកប្រាក់ចំនួន ៣៥៣ លានយ៉េន និង SCHOLARSHIP1012 មានទឹកប្រាក់ចំនួន ៣០៦ លានយ៉េន

៣- គម្រោងសាងសង់ស្ពានអ្នកលឿង (Bridge 2014) មានទឹកប្រាក់ចំនួន ១១.៩៤០ លានយ៉េន ។

រីឯគម្រោងដែលបានផ្តល់នាឆ្នាំកន្លងមក និងបានបញ្ចប់ក្នុងឆមាសទី១ ឆ្នាំ២០១១ មាន៖

១- គម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម

២- គម្រោងជីកអណ្តូងទឹកស្អាតស្រុកមេមត់ ខេត្តកំពង់ចាម

៣- គម្រោងសាងសង់សាលាបឋមសិក្សានៅរាជធានីភ្នំពេញ

៤- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស SCHOLARSHIP 0710

៥- គម្រោងសាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ និង

៦- គម្រោងស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ១ (ជំហានទី៣) ។

**ក.២- ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង**

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ រដ្ឋាភិបាលជប៉ុនពុំបានផ្តល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជាទេ ។

**ខ- កម្ចីសម្បទានរាជរដ្ឋាភិបាលជប៉ុន**

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាពុំបានទទួលកម្ចីសម្បទានពីរាជរដ្ឋាភិបាលជប៉ុនទេ ។ ចំពោះកម្ចីសម្បទានដែលបានផ្តល់កន្លងមកហើយកំពុងអនុវត្តមិនទាន់ចប់មាន៖

១- គម្រោងអភិវឌ្ឍន៍ផែពហុបំណងរបស់កំពង់ផែក្រុងព្រះសីហនុ (L/A No.CP-P10) មានទឹកប្រាក់ចំនួន ៧.១៧៦ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

២- គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅនិរោធ (L/A No.CP-P9) មានទឹកប្រាក់ចំនួន ៣.៥១៣ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

៣- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (L/A No.CP-P8) មានទឹកប្រាក់ចំនួន ៣.៦៥១ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៨)

៤- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P7) មានទឹកប្រាក់ចំនួន ២.៦៣២ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៧)

៥- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (L/A No.CP-P6) មានទឹកប្រាក់ចំនួន ៣១៨ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៦)

៦- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P5) មានទឹកប្រាក់ចំនួន ៣.០២៩ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

**៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ**

ក្នុងឆមាសទី១ ឆ្នាំ២០១១ ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការមានចំនួន ៣.២៧៤,៣ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១០ កើនឡើង ១,៥% ក្នុងនោះ ចំណូលពីឃ្លាំងសម្របសម្រួលបោះផ្សាយកើនឡើង ១៥៩,៨ ពាន់លានរៀល (១០,៥%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជាកើនឡើង ៨,១ ពាន់លានរៀល (២,៩%) ចំណូលពីសាខាធនាគារជាតិនៃកម្ពុជាកើនឡើង ១៤,៧ ពាន់លានរៀល (៨,៥%) និងចំណូលផ្សេងៗកើនឡើង ៥៣,៧ ពាន់លានរៀល (៥៩,៨%) ។ ប៉ុន្តែក៏មានចំណូលមួយចំនួនថយចុះដែរ ដូចជា ប្រាក់បញ្ញើចរន្តគ្រឹះស្ថានហិរញ្ញវត្ថុថយចុះ ១៤៤,២ ពាន់លានរៀល (១៥,៥%) ចំណូលពន្ធដារ-

ពន្ធគយ ថយចុះ ៣៥,១ ពាន់លានរៀល (១៥,២%) និងចំណូលពីប្រាក់កក់ដេញថ្លៃនិងលក់ដុល្លារថយចុះ ៧,២ ពាន់លានរៀល (១០០%) ។

រីឯចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញ មានចំនួន ៣.២១៦,៤ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១០ កើនឡើង ០,៩% ក្នុងនោះ ចំណាយឱ្យរតនាគារជាតិកើនឡើង ១០៦ ពាន់លានរៀល (១២,៦%) ចំណាយដកប្រាក់បញ្ញើចរន្តគ្រឹះស្ថានហិរញ្ញវត្ថុកើនឡើង ៧១,៣ ពាន់លានរៀល (៣០,៨%) និងចំណាយផ្សេងៗកើនឡើង ៥៧,២ ពាន់លានរៀល (៥៤,១%) ។ ប៉ុន្តែក៏មានចំណាយមួយចំនួនថយចុះដែរ ដូចជា ចំណាយបញ្ជូនទៅឃ្លាំងសម្របសម្រួលបោះផ្សាយថយចុះ ១៥៤,៧ ពាន់លានរៀល (១០,៣%) ចំណាយឱ្យសាខាធនាគារជាតិនៃកម្ពុជាថយចុះ ៤១,៧ ពាន់លានរៀល (៨,៥%) ចំណាយដកប្រាក់បញ្ញើអគ្គិសនីកម្ពុជាថយចុះ ៨,២ ពាន់លានរៀល (១០០%) និងចំណាយដកប្រាក់កក់ដេញថ្លៃដុល្លារថយចុះ ២,៦ ពាន់លានរៀល (១០០%) ។

ក្នុងគ្រានេះដែរ សកម្មភាពប្រាក់ដុល្លារអាមេរិកបង់ចូលតាមបេឡាប្រតិបត្តិការ មានចំនួន ១.៤២៨,៦ លានដុល្លារអាមេរិក កើនឡើង ១៣,៤ លានដុល្លារអាមេរិក (០,៩%) ហើយចំណា យតាមបេឡាប្រតិបត្តិការ មានចំនួន ១.៤២៨,៨ លានដុល្លារ កើនឡើង ១៣,១ លានដុល្លារ (០,៩%) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១០។

ដើម្បីសម្រួលដល់ចរាចរណ៍ក្រដាសប្រាក់រៀល ធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជា បានដូរយកក្រដាសប្រាក់ ចាស់ ទក់ រហែកចំនួន ១៤៧,៥ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ ២០១០ កើនឡើង ១៩,៥ ពាន់លានរៀល (១៥,២%) ហើយបានធ្វើការកាត់កម្ទេច និងបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក ដោយម៉ាស៊ីនធម្មតា ចំនួន ៣៦២,២ ពាន់លានរៀល កើនឡើង ៩,៣ ពាន់លានរៀល (២,៦%) និងសាច់ប្រាក់ដែលបានកាត់កម្ទេចដោយម៉ាស៊ីនស្វ័យប្រវត្តិចំនួន ១៨០,១ ពាន់លានរៀល ថយចុះ ២២,៨ ពាន់លានរៀល (១១,២%) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១០ ។

ចំពោះការងារគ្រប់គ្រងសាច់ប្រាក់ និងការងាររាំងខ្ទប់ក្រដាសប្រាក់ក្លែងក្លាយ ធនាគារជាតិនៃកម្ពុជា តែងតែតាមដាន និងធ្វើការអង្កេតជាប្រចាំ ។ ធនាគារជាតិនៃកម្ពុជា បានដកហូតក្រដាសប្រាក់រៀល ក្លែងក្លាយ (ថតចម្លង) ចំនួន ១២៨ សន្លឹក និងបានសហការជាមួយធនាគារ UOB (United Overseas Bank Limited) រៀបចំសិក្ខាសាលាស្តីពី ការពិនិត្យក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយចំនួន ១ លើក ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ មានអ្នកចូលរួមចំនួន ៤៩ នាក់ ដែលជាមន្ត្រីបុគ្គលិកមកពីមន្ទីរស្ថាប័នរដ្ឋ និងគ្រឹះស្ថានធនាគារហិរញ្ញវត្ថុ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង ។

### ៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាតិទូទាត់សងប្រាក់ ដែលបានចាប់ផ្តើមកាលពីត្រីមាសទី៣ នៃឆ្នាំ២០១០ ដោយផ្តោតជាសំខាន់ទៅលើការបំពាក់ហាដវែរ (hardware) សម្រាប់ប្រព័ន្ធ និងការងារសិក្សានិងរចនាសូវវែរ (software) ជាមួយក្រុមហ៊ុនស៊ីអ៊ឹមអេ (CMA Small System AB) ដើម្បីរៀបចំប្រព័ន្ធទូទាត់និងផាត់ទាត់ ដែលគ្រោងនឹងដាក់ឲ្យប្រើប្រាស់នៅដើមឆ្នាំ២០១២ ។ តាមរយៈគម្រោងអភិវឌ្ឍន៍ប្រព័ន្ធពេញលេញនេះ ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដូចជា មូលប្បទានបត្រ

និងបញ្ញាទូទាត់ ជាដើម នឹងអាចត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់សងប្រាក់ ដែលការផាត់ទាត់ និងទូទាត់ឧបករណ៍ទាំងនេះនឹងត្រូវបានប្រមូលផ្តុំនៅទីស្នាក់ការកណ្តាលរបស់ធនាគារជាតិនៃកម្ពុជា ។ ប្រព័ន្ធពេញលេញនេះ នឹងត្រូវបានប្រើជំនួសប្រព័ន្ធបណ្តោះអាសន្នដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ។ នាបច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាត្រៀមកែលម្អ Client Module ដែលកំពុងត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានធនាគារជាសមាជិកសភាផាត់ទាត់ ដើម្បីឲ្យស្របតាមតម្រូវការថ្មីនៃប្រព័ន្ធដែលមានលក្ខណៈពេញលេញនេះ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការផាត់ទាត់ និងទូទាត់ ។

ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់ ។

### ៩- ការងារព័ត៌មានវិទ្យា

ការងារព័ត៌មានវិទ្យាក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ធនាគារជាតិនៃកម្ពុជាបានផ្តោតសំខាន់លើគម្រោងធំៗពីរ ទីមួយគឺ ការដាក់ឲ្យដំណើរការប្រព័ន្ធធនាគារស្នូលនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស និងទីពីរគឺ ការអនុវត្តគម្រោងប្រព័ន្ធជាតិទូទាត់សងប្រាក់ ។ ចំពោះការដាក់ឲ្យដំណើរការប្រព័ន្ធធនាគារស្នូល ធនាគារជាតិនៃកម្ពុជាបានដំឡើងប្រព័ន្ធនេះនៅសាខាធនាគារជាតិនៃកម្ពុជាដែលនៅសល់ ចំនួន ១០ គឺសាខាខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ស្ពឺ កំពត ក្រចេះ ស្ទឹងត្រែង កំពង់ធំ ពោធិ៍សាត់ និងរតនគីរី ។ ចំណែកឯគម្រោងប្រព័ន្ធជាតិទូទាត់សងប្រាក់ ក្រុមការងារធនាគារជាតិនៃកម្ពុជាបានរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលរួមមាន Network Infrastructure និងប្រព័ន្ធមណ្ឌលទិន្នន័យសង្គ្រោះក្នុងគ្រាអាសន្ន ។ សម្រាប់ដំណើរការប្រព័ន្ធនេះក្រុមការងារក៏កំពុងសិក្សា Functional Specifications របស់ប្រព័ន្ធនេះ ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គីមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក ។ |

ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៣ លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួន ដូចខាងក្រោម៖

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៤ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ អំពី (១) របាយការណ៍ស្តីពី

ការកែសម្រួល និងបន្ថែមសមាសភាពក្រុមលេខាធិការក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា (២) ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១០ និង (៣) របាយការណ៍ស្តីពីការពង្រឹងការប្រើប្រាស់ប្រាក់រៀល

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៥ នាថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១១ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ស្តីពី ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១០ និងផែនការឆ្នាំ២០១១
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៦ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា ។

## ២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

### ២.១- ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាល) ក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន ៨៧០រូប (ប្រុស ៤៩២រូប ស្រី ៣៧៨រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក្នុងឆមាសទី១ ឆ្នាំ២០១១ មានចំនួន ៣៩២រូប (ប្រុស ២២៦រូប ស្រី ១៦៦រូប) ។

ដូច្នេះសរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងឆមាសទី១ ឆ្នាំ២០១១នេះ មានចំនួន ១២៦២រូប (ប្រុស ៧១៨រូប ស្រី ៥៤៤រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌក្នុងខែធ្នូ ឆ្នាំ២០១០ ដែលមានចំនួន ១២៥៥រូប (ប្រុស ៧១០រូប ស្រី ៥៤៥រូប) មានការប្រែប្រួលដូចតទៅ៖

+ ទីស្នាក់ការកណ្តាល គឺកើនចំនួន ០១រូប (ចូល ០៩រូប ចេញ ០៨រូប)
+ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត គឺកើនចំនួន ០៦រូប ( ចូល ២០រូប ចេញ ១៤រូប) ។

### ២.២- ការងារបណ្តុះបណ្តាល

#### ក- ការងារបណ្តុះបណ្តាលក្នុងប្រទេស

ការអភិវឌ្ឍធនធានមនុស្សក្នុងឆមាសទី១ ឆ្នាំ២០១១នេះ ធនាគារជាតិនៃកម្ពុជាបានបន្តបើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាចំនួន ២ (មន្ត្រីបុគ្គលិកចូលរួមចំនួន២៧នាក់) វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាចំនួន ៤លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ១៨១នាក់) វគ្គសិក្សារយៈពេលវែងនៅសាលាភូមិន្ទរដ្ឋបាល (មន្ត្រីចូលរួមចំនួន ២រូប) វគ្គបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ (មន្ត្រីបុគ្គលិកកំពុងសិក្សាសរុបចំនួន ១៣រូប សម្រាប់ជំនាន់ទី១៩ ចំនួន ៥រូប និងជំនាន់ទី២០ចំនួន ៨រូប) និងចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗ តាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាចំនួន ២លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៣រូប) ។

#### ខ- ការងារបណ្តុះបណ្តាលក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេសតាមរយៈ

សិក្ខាសាលាចំនួន ៥១លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៨៤រូប) ទស្សនកិច្ចសិក្សាចំនួន ០៤លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ២០រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ៨លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ១២រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២លើក នៅប្រទេសញូហ្សេឡែន និងអូស្ត្រាលី (មន្ត្រីបុគ្គលិកចូលរួមចំនួន ២រូប) និងកិច្ចប្រជុំនានាចំនួន ៣៩លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៧៨រូប) តាមការអញ្ជើញនិងឧបត្ថម្ភរបស់ប្រទេស និងស្ថាប័នអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលនៃប្រទេសតណ្ហា រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មជ្ឈមណ្ឌល SEACEN ធនាគារកណ្តាលសាធារណរដ្ឋឆែក ធនាគារកណ្តាលអាល្លឺម៉ង់ និងស្ថាប័នផ្សេងៗទៀត ។

**៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**

ក្នុងឆមាសទី១ ឆ្នាំ២០១១នេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារសវនកម្មផ្ទៃក្នុងឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយបានបន្តបំពាក់បំប៉ននូវគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងដល់មន្ត្រីបុគ្គលិកបណ្តាសាខាធនាគារជាតិនៃកម្ពុជាឲ្យកាន់តែយល់ច្បាស់ថែមទៀត ។ ទន្ទឹមនឹងនេះ មន្ត្រីសវនកម្មបានចុះប្រមូលព័ត៌មានអំពី លំហូរការងារដែលពាក់ព័ន្ធនឹងប្រព័ន្ធធនាគារស្នូលនៅនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគណនេយ្យ និងនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់នៃធនាគារជាតិនៃកម្ពុជា លើប្រតិបត្តិការវិនិយោគទុនបម្រុង ការផ្ទេរប្រាក់ពីធនាគារជាតិទៅសាខាខេត្ត ការផ្ទេរប្រាក់ពីសាខាមកធនាគារជាតិនៃកម្ពុជា និងការបើក-បិទគណនី ។ ម្យ៉ាងវិញទៀត មន្ត្រីសវនកម្មបានចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជា រួមមានៈ ខេត្តស្វាយរៀង កំពង់ឆ្នាំង និងសាខាធនាគារជាតិនៃកម្ពុជារាជធានីភ្នំពេញ ។ បន្ទាប់ពីការធ្វើសវនកម្ម របាយការណ៍ដែលរួមមានអនុសាសន៍មួយចំនួនផង ត្រូវបានដាក់ចេញដើម្បីធ្វើការកែលម្អ ។

ក្រៅពីការចុះធ្វើសវនកម្ម មន្ត្រីសវនកម្មបានចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានដាក់ចុះនៅតាមសាខាធនាគារជាតិនៃកម្ពុជាជាប្រចាំ ។ បច្ចុប្បន្ន មន្ត្រីសវនកម្មបាននិងកំពុងពិនិត្យលើប្រតិបត្តិការ នៅនាយកដ្ឋានមួយចំនួននិងនៅសាខាធនាគារជាតិនៃកម្ពុជាទាក់ទងនឹងការងារគ្រប់គ្រងសាច់ប្រាក់ និងតាមដានដំណើរការប្រព័ន្ធធនាគារស្នូល ដើម្បីពិនិត្យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ប្រតិបត្តិការនីមួយៗឲ្យបានល្អ បង្ការហានិភ័យ ព្រមទាំងផ្តល់នូវសេវាកម្មដ៏ល្អប្រសើរ និងបង្កើនជំនឿទុកចិត្តចំពោះប្រព័ន្ធធនាគារដល់អតិថិជន ។ ជាលទ្ធផល សាខាធនាគារជាតិនៃកម្ពុជាបានកែលម្អតាមអនុសាសន៍បានល្អមួយចំនួនធំ ។

ក្នុងឆមាសទី១ ឆ្នាំ២០១១នេះ ការងារអធិការកិច្ចត្រូវបានដំណើរការតាមរយៈការចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនលើសាខាធនាគារជាតិនៃកម្ពុជាចំនួន ៧ ដែលការចុះត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវឌ្ឍិនិងវិន័យការងារមន្ត្រីបុគ្គលិកនៅតាមសាខាឲ្យបានកាន់តែប្រសើរ។

ទន្ទឹមនឹងនេះ ការត្រួតពិនិត្យនៅកន្លែងក៏បានដំណើរការជាប្រចាំតាមរយៈរបាយការណ៍ប្រចាំខែរបស់បណ្តានាយកដ្ឋាននៅទីស្នាក់ការកណ្តាល និងនៅសាខាធនាគារជាតិនៃកម្ពុជា ដោយបានពិនិត្យឡើងវិញអំពីការអនុវត្តតាមមុខងារភារកិច្ច និងផ្ទៀងផ្ទាត់នូវទិន្នន័យរបស់បណ្តាអង្គភាពពាក់ព័ន្ធ ដើម្បីរកឲ្យឃើញនូវ

ភាពត្រឹមត្រូវប្រាកដប្រជា ។

### ៤- ការខារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ធនាគារជាតិនៃកម្ពុជាបានកំពុងបន្តពង្រឹងប្រតិបត្តិការរបស់ខ្លួន ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចសហប្រតិបត្តិការតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឲ្យកាន់តែមានប្រសិទ្ធភាពនិងបានដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) បានគ្រប់សាខារាជធានី-ខេត្ត ព្រមទាំងបានបណ្តុះបណ្តាលនិងផ្គត់ផ្គង់ធនធានមនុស្សដើម្បីអនុវត្តភារកិច្ចនេះ ។ ដោយឡែកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងបន្តសាកល្បងជំហានទី១ លើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋ ដែលតម្រូវឲ្យរតនាគារខេត្តទាំងពីរ គឺខេត្តកណ្តាល និងខេត្តបន្ទាយមានជ័យ បើកគណនីប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋនៅធនាគារអេស៊ីលីដា និងក៏បានសាកល្បងជំហានទី២ គឺធនាគារអេស៊ីលីដា បន្តទទួលយករតនាគារខេត្តកំពង់ចាម មណ្ឌលគិរី ស្ទឹងត្រែង កោះកុង ព្រះវិហារ ឧត្តរមានជ័យ និងធនាគារកាណាឌីយ៉ា ទទួលយករតនាគារខេត្តសៀមរាប បាត់ដំបង និងព្រះសីហនុ ហើយរតនាគារខេត្តបានបិទគណនីនៅសាខាធនាគារខេត្ត ។

ក្នុងដើមឆមាសទី១ នេះដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុញ្ញាតឲ្យសាលាស្រុក-ក្រុង ទាំង ៣ រួមមាន ស្រុកពាមរក៍ (ខេត្តព្រៃវែង) ក្រុងស្ទឹងសែន (ខេត្តកំពង់ធំ) និងក្រុងក្រចេះ (ខេត្តក្រចេះ) បើកគណនីប្រាក់បញ្ញើនៅសាខាធនាគារជាតិនៃកម្ពុជា ។

## III- ទំនាក់ទំនងអន្តរជាតិ

### ១- ទំនាក់ទំនងពហុភាគី

#### ១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១១ នេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានមកបំពេញទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជា ចំនួន ២លើក ដែលលើកទី១ នៅថ្ងៃទី២១-២៨ ខែមីនា ឆ្នាំ២០១១ ស្តីពី ការវាយតម្លៃជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា និងលើកទី២ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ ស្តីពី ស្ថានភាពសេដ្ឋកិច្ច និងការពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។ គោលបំណងនៃបេសកកម្ម គឺបានផ្តោតសំខាន់លើ ការវាយតម្លៃលើស្ថានភាពបច្ចុប្បន្ននៃស្ថិរភាពវិស័យហិរញ្ញវត្ថុ ប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសវនកម្មផ្ទៃក្នុង និងក្របខ័ណ្ឌបទប្បញ្ញត្តិ ព្រមទាំងប្រសិទ្ធភាពនៃមូលនិធិដែលបានផ្តល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិតាមរយៈជំនួយបច្ចេកទេសនានាសម្រាប់ធនាគារជាតិនៃកម្ពុជា ។ ជារួម ក្រុមបេសកកម្មបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាបានស្ថិរភាពហិរញ្ញវត្ថុ និងការទប់ទល់ទាន់ពេលវេលាចំពោះវិបត្តិហិរញ្ញវត្ថុសកលនាពេលថ្មីៗកន្លងទៅនេះ ។

ចំណែកគោលបំណងនៃក្រុមបេសកកម្មលើកទី២ គឺបានផ្តោតសំខាន់លើៈ (១) ទិសដៅម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១១ (២) នយោបាយរូបិយវត្ថុនិងប្តូរប្រាក់ (៣) បញ្ហានានាទាក់ទងនឹងប្រតិបត្តិការរូបិយវត្ថុ ដូចជាដំណើរការពង្រឹងក្របខ័ណ្ឌរូបិយវត្ថុបច្ចុប្បន្ន (៤) ការត្រួតពិនិត្យប្រព័ន្ធធនាគារ ភាពរឹងមាំវិស័យហិរញ្ញវត្ថុ និងការអនុវត្តប្រឆាំងការសំអាតប្រាក់ និង (៥) ប្រធានបទទាក់ទងនឹងមាត្រាទី៤ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ

ឆ្នាំ២០១១ ។ ជារួម ក្រុមបេសកកម្មបានកោតសរសើរស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដែលរក្សាបានកំណើនសេដ្ឋកិច្ចបង្គួរ ទន្ទឹមនឹងស្ថិរភាពអតិផរណា ព្រមទាំងការរីកដុះដាលវិស័យហិរញ្ញវត្ថុ ការកើនឡើងបរិមាណធនាគារ និងភាពរឹងមាំវិស័យហិរញ្ញវត្ថុតាមរយៈកម្មវិធីបង្កើនដើមទុនរបស់ធនាគារ ក្នុងបរិការណ៍វិបត្តិសេដ្ឋកិច្ចសកល ។

**១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី**

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជំហានទី២ (FSPL II) នៃផែនការ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥**" ត្រូវបានបញ្ចប់ប្រកបដោយជោគជ័យកាលពីខែធ្នូ ឆ្នាំ២០១០ កន្លងមកនេះ ។ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ជំនួយបច្ចេកទេសសម្រាប់ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ និងរៀបចំសំណុំកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ជំហានទី៣ (FSPL III) បន្តទៀត ។ ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រនេះរួមមាន ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មការមូលបត្រកម្ពុជា ។ ក្រុមការងារជំនួយបច្ចេកទេសបានចាប់ផ្តើមរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនេះនៅខែតុលា ឆ្នាំ២០១០ និងបានដាក់ជូនពិនិត្យជាលើកដំបូងកាលពីខែមករា ឆ្នាំ២០១១ ។ បច្ចុប្បន្ន សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនេះកំពុងស្ថិតក្នុងការសិក្សា និងក្នុងការពិភាក្សាផ្តល់យោបល់ពីស្ថាប័នពាក់ព័ន្ធនៅឡើយ ហើយគ្រោងនឹងបញ្ចប់ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័ត នាខែសីហា ខាងមុខនេះ ។

**១.៣- ទំនាក់ទំនងជាមួយអាស៊ាន**

**១.៣.១- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន**

ក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ធនាគារជាតិនៃកម្ពុជាបន្តចូលរួមយ៉ាងសកម្ម ដើម្បីផ្លាស់ប្តូរបទពិសោធន៍លើវិស័យសេដ្ឋកិច្ច/ហិរញ្ញវត្ថុ និងចូលរួមយ៉ាងយកចិត្តទុកដាក់ក្នុងការពង្រឹងវឌ្ឍនភាពសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ ។ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរង និងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី៤ អំពីសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ នៅប្រទេសកម្ពុជាប្រកបដោយជោគជ័យ ។ ក្នុងឆមាសនេះដែរ គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៧ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាលនិងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងចំណោមអាស៊ាន១០ ព្រមទាំងអាស៊ាន+៣ (ចិន ជប៉ុន និងកូរ៉េ) ដែលបានរៀបចំឡើង នៅថ្ងៃទី៥-៨ ខែមេសា ឆ្នាំ២០១១ នៅប្រទេសឥណ្ឌូណេស៊ី ។

ជាលទ្ធផល កិច្ចប្រជុំមានគោលបំណងជំរុញយន្តការសមាហរណកម្មរូបិយវត្ថុនិងហិរញ្ញវត្ថុអាស៊ានឲ្យបានស៊ីជម្រៅថែមទៀត ដើម្បីឈានទៅរកការបើកចំហវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ នៅឆ្នាំ២០១៥ ខាងមុខ ស្របតាមផែនការយុទ្ធសាស្ត្រសមាហរណកម្មអាស៊ាន ដែលផ្តោតទៅលើវិស័យជាអាទិភាពចំនួន ៤ គឺៈ ការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់និងផាត់ទាត់ ។

ទន្ទឹមនោះ ការចរចាជុំទី៥នៃការបើកចំហវិស័យហិរញ្ញវត្ថុត្រូវបានបញ្ចប់ និងចុះហត្ថលេខាដោយប្រទេសជាសមាជិកអាស៊ាន នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១១ នៅប្រទេសវៀតណាម បន្ទាប់ពីបានប្រកាសជាផ្លូវការដើម្បីចាប់ផ្តើមដំណើរការចរចាជុំទី៦នៃការបើកចំហវិស័យហិរញ្ញវត្ថុ ដែលដឹកនាំដោយប្រទេសម៉ាឡេស៊ី ។

លើសពីនេះ អាស៊ានកំពុងរៀបចំ "ផែនការយុទ្ធសាស្ត្ររយៈកាល ១០ឆ្នាំ សម្រាប់សមាហរណកម្មអាស៊ាន ២០១១-២០២០" លើវិស័យហិរញ្ញវត្ថុ រួមទាំងប្រព័ន្ធទូទាត់ក្នុងតំបន់ផងដែរ ហើយផែនការយុទ្ធសាស្ត្រនេះ រំពឹងថានឹងត្រូវបានអនុម័តនៅឆ្នាំ២០១១ នេះ ។

### ១.៣.២- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣

សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ មកទល់បច្ចុប្បន្ននេះ មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ។ កិច្ចព្រមព្រៀង "ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)" ដែលជាមូលនិធិរួមក្នុងតំបន់មានទឹកប្រាក់សរុបចំនួន ១២០ ពាន់លានដុល្លារអាមេរិក ត្រូវបានចូលជាធរមានកាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ និងបានប្រកាសឲ្យមានដំណើរការជាផ្លូវការនៅខែឧសភា ឆ្នាំ២០១០ ។ គំនិតផ្តួចផ្តើមនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុក្នុងតំបន់ សំដៅជួយដល់ប្រទេសជាសមាជិកណាដែលជួបបញ្ហាជញ្ជីងទូទាត់ និងសាច់ប្រាក់ងាយស្រួលរយៈពេលខ្លី ក្នុងពេលមានវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (AMRO) ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ត្រូវបានបង្កើតឡើង និងដើរតួនាទីយ៉ាងសំខាន់ក្នុងការតាមដាន ត្រួតពិនិត្យ និងវិភាគស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ សំដៅចូលរួមបង្ការហានិភ័យជាមុន ចាត់វិធានការទាន់ពេលវេលា និងជួយដល់ការធ្វើសេចក្តីសម្រេចចិត្តនៃដំណើរការស្វប់របស់ CMIM ប្រកបដោយប្រសិទ្ធភាព ។

លើសពីនេះ ប្រទេសអាស៊ាន+៣ ក៏បានចូលរួមអភិវឌ្ឍ និងពង្រឹងគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន (ABMI) ប្រកបដោយជោគជ័យផងដែរ ។ គំនិតផ្តួចផ្តើមនេះបានចូលរួមអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ ប្រកបដោយប្រសិទ្ធភាព និងសាច់ប្រាក់ងាយស្រួល ដើម្បីអនុញ្ញាតឲ្យមានការប្រើប្រាស់សញ្ជ័យសម្រាប់វិនិយោគទុននៅក្នុងប្រទេសអាស៊ីផ្ទាល់ ។ ដើម្បីគាំទ្រការចេញផ្សាយសញ្ញាប័ណ្ណសាជីវកម្មនិងការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ឲ្យកាន់តែទូលំទូលាយ ប្រទេសអាស៊ានរួមជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតនូវយន្តការធានាលើឥណទាននិងវិនិយោគ ដែលមានទឹកប្រាក់ចំនួន ៧០០ លានដុល្លារអាមេរិក ។ ខ្លឹមសារនៃកិច្ចព្រមព្រៀងបង្កើតយន្តការនេះបានឯកភាព និងប្រកាសជាផ្លូវការរួចហើយ នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៅទីក្រុងតាស្សកិន កាលពីខែឧសភា ឆ្នាំ២០១០ កន្លងមកនេះ ដែលរំពឹងថានឹងចុះហត្ថលេខាក្នុងពេលខ្លីខាងមុខនេះ ។ ទន្ទឹមនឹងនោះ វេទិកាទីផ្សារសញ្ញាប័ណ្ណអាស៊ាន+៣ ក៏បានបង្កើតឡើងដើម្បីជួយដល់ការអនុវត្តទីផ្សារប្រកបដោយស្តង់ដារ និងសម្របសម្រួលបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការសញ្ញាប័ណ្ណឆ្លងកាត់ព្រំដែនក្នុងតំបន់ ។

### ១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន - SEACEN)

សមាជិកភាពរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងមជ្ឈមណ្ឌលស៊ាសិន (SEACEN) បានផ្តល់ឱកាសជាច្រើនចំពោះធនាគារជាតិនៃកម្ពុជាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវលើវិស័យ

ហិរញ្ញវត្ថុនិងធនាគារ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងជំនឿទុកចិត្តលើប្រតិបត្តិការរបស់ធនាគារកណ្តាល ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការពង្រឹងវិស័យធនាគារ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាសមាជិកនៃមជ្ឈមណ្ឌលស៊ាសិន ធនាគារជាតិនៃកម្ពុជា មានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាថ្នាក់នាយកប្រតិបត្តិ SEACEN-BIS ក្រោមប្រធានបទស្តីពី "ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុៈ ស្ថិរភាពហិរញ្ញវត្ថុនិងកំណើនសេដ្ឋកិច្ច" និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (EXCO) លើកទី៩ កាលពីថ្ងៃទី ១៩ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញប្រកបដោយជោគជ័យ ។ កិច្ចប្រជុំមានគោលបំណងពិភាក្សាលើៈ (i) ពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តទិសដៅយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលស៊ាសិន និងពិភាក្សាពីថវិកាសម្រាប់ឆ្នាំក្រោយ (ii) អនុម័តលើសំណើកម្មវិធីសកម្មភាព ថវិកា និងកិច្ចសហប្រតិបត្តិការប្រចាំឆ្នាំ និង (iii) ពិភាក្សាលើបញ្ហានិងគោលនយោបាយនៃយុទ្ធសាស្ត្រ ដែលមានសារៈសំខាន់សម្រាប់មជ្ឈមណ្ឌលស៊ាសិន ដែលនឹងត្រូវបានផ្តល់ជាអនុសាសន៍ និងដឹកនាំដោយសិក្ខាសាលាលើប្រធានបទដែលត្រូវកំណត់ក្នុងកិច្ចពិភាក្សាជាមួយ EXCO ។

ធនាគារជាតិនៃកម្ពុជា ក៏បានបញ្ជូនមន្ត្រីជាបន្តបន្ទាប់ឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំសំខាន់ៗនានានៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការស៊ាសិន ដែលបានប្រព្រឹត្តទៅនៅបណ្តាប្រទេសសមាជិកស៊ាសិនផងដែរ ។

### ១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន - Francophone)

បន្ទាប់ពីបានចូលជាសមាជិកនា ឆ្នាំ១៩៩៣ មក កិច្ចសហប្រតិបត្តិការជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) កាន់តែមានប្រសិទ្ធភាព និងជិតស្និទ្ធបន្ថែមទៀត ជាពិសេស ការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានទៅវិញទៅមក និងស្វែងរកជំនួយឧបត្ថម្ភពីសំណាក់ធនាគារកណ្តាលជាដៃគូ ។

ដើម្បីពង្រឹងនូវកិច្ចសហប្រតិបត្តិការជាមួយបណ្តាសមាជិកនៃហ្វ្រង់កូហ្វូន ធនាគារជាតិនៃកម្ពុជា មានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី១៨ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១១-១៣ ខែឧសភា ឆ្នាំ២០១១ នៅខេត្តសៀមរាប ។

## ២- ទំនាក់ទំនងទ្វេភាគី

ទន្ទឹមនឹងជំនួយពហុភាគី សមិទ្ធផលទាំងឡាយដែលជាចំណែកមួយនៃកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងធនាគារជាតិនៃកម្ពុជា និងបណ្តាធនាគារកណ្តាលដទៃទៀត ដើម្បីសម្រេចបាននូវគោលដៅរួម គឺការពង្រឹងប្រព័ន្ធធនាគារជាទូទៅនៅក្នុងបរិស្ថានសេដ្ឋកិច្ចពិភពលោកមួយដែលកាន់តែមានលក្ខណៈជាសកល ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ធនាគារជាតិនៃកម្ពុជាតែងតែបានទទួលជំនួយបច្ចេកទេសពីសំណាក់ធនាគារកណ្តាលអាល្លឺម៉ង់ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីរួមចំណែកលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងទិសដៅអភិវឌ្ឍប្រព័ន្ធធនាគារឲ្យកាន់តែរឹងមាំថែមទៀត ។ ជាក់ស្តែង ក្នុងឆមាសទី១ ឆ្នាំ២០១១ នេះ ធនាគារកណ្តាលអាល្លឺម៉ង់បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី

បុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួនពីរលើក លើប្រធានបទពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ និងគោលនយោបាយរូបិយវត្ថុ ។

លើសពីនេះទៀត កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ុងហ្គោលី បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១១ នៅប្រទេសម៉ុងហ្គោលី ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុម៉ាក្រូសេដ្ឋកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្ស ។

ជាមួយគ្នានេះដែរ កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការផ្តល់ជំនួយផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ។ ជាក់ស្តែង កាលពីថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០១១ ធនាគារកណ្តាលថៃបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធផាត់ទាត់និងទូទាត់ នៅធនាគារជាតិនៃកម្ពុជា។

## សន្និដ្ឋាន

សេដ្ឋកិច្ចពិភពលោកបានបង្ហាញពីការងើបឡើងវិញពីវិបត្តិ ទោះបីការងើបឡើងវិញនេះនៅមានលក្ខណៈមិនស្មើតាមតំបន់និងមិនទាន់មានភាពរឹងមាំនៅឡើយ ។ កំណើនភាគច្រើននៅពឹងផ្អែកលើវិធានការរិក្តារកម្មដោយសារតម្រូវការរបស់វិស័យឯកជននៅមានភាពទន់ខ្សោយ ហើយអត្រានិកម្មភាពមានកម្រិតខ្ពស់ នៅឡើយ ។

សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញជាថ្មី ហើយរំពឹងថានឹងបន្តសន្ទុះកំណើនដ៏ប្រសើរ អាស្រ័យដោយអំណោយផលនៃទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ។ កម្ពុជាមានសក្តានុពលដ៏ច្រើនសម្រាប់ការរីកចម្រើន ។ ដើម្បីសម្រេចសក្តានុពលនេះ ជាសំខាន់ត្រូវសិក្សាដកស្រង់បទពិសោធន៍ពីវិបត្តិថ្មីៗនេះ ហើយជំរុញការអនុវត្តកំណែទម្រង់ចាំបាច់ទាំងឡាយ បង្កើនការកសាងនិងកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលទ្រទ្រង់ដល់សកម្មភាពវិស័យឯកជន និងពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងលើកកម្ពស់សមត្ថភាពធនធានមនុស្ស ។ ដោយឡែក នៅក្នុងប្រព័ន្ធធនាគារ ថ្វីបើវិស័យនេះពុំទទួលរងគ្រោះដោយផ្ទាល់ពីវិបត្តិក្តី តែយើងក៏ត្រូវយកចិត្តទុកដាក់ចំពោះមេរៀនពីវិបត្តិហិរញ្ញវត្ថុពិភពលោកផងដែរ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងបន្តអនុវត្តកំណែទម្រង់តាមទិសដៅចង្អុលក្នុង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥" ប្រកបដោយលក្ខណៈបត់បែនទន់ភ្លន់តាមសន្ទុះនៃការប្រែប្រួលបរិស្ថានសេដ្ឋកិច្ច ហិរញ្ញវត្ថុផ្ទៃក្នុងនិងក្រៅប្រទេស ដោយផ្តោតជាចម្បងលើការដាក់ចេញនូវវិធានការសមស្រប ដើម្បីលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ សម្រួលឲ្យវិស័យនេះមានការវិវឌ្ឍប្រកបដោយចីរភាព និងដើម្បីធានាថាប្រព័ន្ធធនាគាររួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

គោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា គឺនឹងបន្តទ្រទ្រង់ចំពោះការខិតខំរបស់រាជរដ្ឋាភិបាលសំដៅជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវភារកិច្ចរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ ។ គោលនយោបាយរូបិយវត្ថុនឹងត្រូវបន្តអនុវត្តដោយផ្អែកលើគោលការណ៍ទីផ្សារ ដូច្នេះហើយនយោបាយប្តូរប្រាក់ដែលជាសមាសធាតុដ៏សំខាន់មួយនៃគោលនយោបាយរូបិយវត្ថុ ត្រូវតែមានលក្ខណ :អណ្តែតទន់ភ្លន់ តម្លាភាព និងសម្របតាមមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ដើម្បីធានាប្រសិទ្ធភាពក្នុងការបែងចែកធនធានក្នុងសេដ្ឋកិច្ច និងធានាថែរក្សាទុនបម្រុងអន្តរជាតិក្នុងកម្រិតមួយសមស្រប ដើម្បីជាខែលការពារសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុក្នុងគ្រាមានវិបត្តិជាយថាហេតុ ។ ជាគោលដៅ ធនាគារជាតិនៃកម្ពុជានឹងខិតខំរក្សាកម្រិតអតិផរណានាឆ្នាំនេះនិងឆ្នាំខាងមុខក្នុងអត្រាមួយខ្ទង់ ព្រមទាំងរក្សាស្ថិរភាពប្រាក់រៀល ស្របនឹងការជំរុញលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិឲ្យបានទូលាយថែមទៀត ។

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅនៅក្នុង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០១៥" អំពីការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ច ។ ជាមួយនឹងការរីកចម្រើនជាលំដាប់នៃសេដ្ឋកិច្ចពាណិជ្ជកម្ម និងការលេចឡើងនៃទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា នេះគឺជាពេលវេលាសមស្របសម្រាប់ពិចារណាអំពីវិធានការ ក្នុងការពង្រឹងក្របខ័ណ្ឌរូបិយវត្ថុ សំដៅធានាចីរភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ដូច្នេះ ការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារហិរញ្ញវត្ថុពីគ្រាដំបូង គឺជាឱកាសដ៏ប្រសើរសម្រាប់ពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការលើកតម្កើងអត្តសញ្ញាណជាតិ និងក៏ជាកត្តាដ៏សំខាន់ផងដែរក្នុងការរក្សាស្ថិរភាពថ្លៃ ស្ថិរភាពប្រាក់រៀល និងការលើកកម្ពស់ តួនាទីជាអ្នកឲ្យខ្ចីចុងក្រោយបង្អស់របស់ធនាគារជាតិនៃកម្ពុជាដែលជាធនាគារកណ្តាល និងជាអាជ្ញាធរបញ្ញត្តិកម្មស្នូលទទួលភារៈរក្សាស្ថិរភាពវិស័យ

ហិរញ្ញវត្ថុ ។ នៅក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាសូមស្វាគមន៍ចំពោះការជ្រោមជ្រែងពីសំណាក់ស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងជួររាជរដ្ឋាភិបាល ព្រមទាំងភ្នាក់ងារសេដ្ឋកិច្ចទាំងឡាយនៅក្នុងវិស័យឯកជន ក្នុងការបង្កើនការប្រើប្រាស់ប្រាក់រៀល ។

ទន្ទឹមនោះ ចំពោះមុខ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងក្របខ័ណ្ឌបញ្ញត្តិកម្ម និងត្រួតពិនិត្យថែមទៀត ព្រមទាំងលើកកម្ពស់ការតាមដានប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ ដើម្បីធានាថា គ្រឹះស្ថានទាំងនោះមានសុវត្ថិភាព ភាពរឹងមាំ និងគុណភាពល្អ ដែលបង្កើនការចូលរួមចំណែករបស់ពួកគេក្នុងការទ្រទ្រង់សម្រេចគោលដៅម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលជាទូទៅ និងគោលដៅនយោបាយរូបិយវត្ថុជាពិសេស ។

# ខ- ទិសដៅការងារឆមាសទី២ ឆ្នាំ ២០១១

## ទិសដៅការងារឆមាសទី២ ឆ្នាំ២០១១

បច្ចុប្បន្ននេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកមានភាពប្រសើរឡើងវិញ ប៉ុន្តែកំណើននេះនៅមិនទាន់មានភាពរឹងមាំ និងគត់មត់ដូចកាលពីមុនពេលមានវិបត្តិនៅឡើយ ដោយឡែក ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏បានបន្តងើបឡើងវិញជាបណ្តើរៗគួរឲ្យកត់សម្គាល់ ។ ផ្អែកតាមស្ថានភាពបច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនក្នុងកម្រិតជាង ៦% ។ ក្នុងឆមាសទី១នេះ ដើម្បីរក្សាឲ្យបាននូវកំណើនសេដ្ឋកិច្ចឲ្យមានចីរភាព ធនាគារជាតិនៃកម្ពុជាបាននិងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុយ៉ាងប្រុងប្រយ័ត្នឲ្យសមស្របទៅតាមការវិវត្តជាក់ស្តែងនៃសេដ្ឋកិច្ច ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបន្តចូលរួមចំណែករក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការពង្រឹងការគ្រប់គ្រងហានិភ័យឲ្យបានសមស្រប និងធ្វើឲ្យប្រសើរឡើងនូវភាពជឿជាក់ក្នុងការធ្វើតេស្តលើភាពទន់ខ្សោយនៃប្រព័ន្ធធនាគារ និងការកែលម្អក្របខ័ណ្ឌគតិយុត្តិដើម្បីសម្រួលដល់ការត្រួតពិនិត្យប្រព័ន្ធធនាគារឲ្យកាន់តែមានប្រសិទ្ធភាព ។ នៅក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅសម្រាប់ឆមាសទី២ ឆ្នាំ២០១១ សំខាន់ៗដូចខាងក្រោម៖

**១. ការងាររូបិយវត្ថុ** (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

- រូបិយវត្ថុទូទៅ (M2) ១៨,៦%
- រូបិយវត្ថុក្នុងចរាចរណ៍ ១៤,៨%
- ប្រាក់បញ្ញើជារូបិយប័ណ្ណ ១៩,៨%
- ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា -៥,៩%
- ឥណទានសុទ្ធចំពោះរាជរដ្ឋាភិបាលពីវិស័យឯកជន -១០,១%
- ទុនបម្រុងផ្លូវការសុទ្ធ ១០,០% ។

**២. ការងារប្តូរប្រាក់ និងគ្រប់គ្រងទុនបម្រុង**

- សិក្សាស្វែងយល់អំពីកត្តាផ្សេងៗដែលមានឥទ្ធិពលលើស្ថានភាពអត្រាប្តូរប្រាក់
- បន្តពង្រឹងសមត្ថភាពក្នុងការងារគ្រប់គ្រងទុនបម្រុងតាមលក្ខណៈបច្ចេកទេស និង
- ត្រៀមលក្ខណៈសាកល្បងវិនិយោគលើសញ្ញាប័ណ្ណផ្សេងៗដើម្បីបង្កើនចំណូល ។

**៣. ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់**

- បន្តអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ និងផាត់ទាត់ ឲ្យបានចប់នៅចុងឆ្នាំ២០១១ ដើម្បីអាចដាក់ឲ្យប្រើប្រាស់នៅដើម ឆ្នាំ២០១២
- សិក្សា និងរកវិធីសាស្ត្រដើម្បីសម្រួលការទូទាត់សាច់ប្រាក់នៅសភាផាត់ទាត់ឲ្យមានប្រសិទ្ធភាព
- ពិនិត្យឡើងវិញនូវវិធាន និងនីតិវិធីសម្រាប់ការទូទាត់សងប្រាក់
- បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់
- រៀបចំបង្កើតក្រុមប្រឹក្សាជាតិទូទាត់សងប្រាក់ ដើម្បីសម្រួលដល់ការពិភាក្សាពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់ ។

## ៤. ការងារត្រួតពិនិត្យ

- បន្តពង្រឹងឲ្យមានភាពសុក្រឹត្យបន្ថែមទៀតលើការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានឥណទាន ដើម្បីផ្តល់នូវព័ត៌មានបន្ថែមសម្រាប់ការតាមដានលើប្រព័ន្ធធនាគារ
- បន្តអនុវត្តការវិភាគស្ថានភាពគ្រឹះស្ថានធនាគារតាមប្រព័ន្ធ COBRA ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- បន្តអនុវត្តការចុះត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារតាមផែនការកំណត់
- បន្តរៀបចំកែលម្អច្បាប់ ប្រកាស បទប្បញ្ញត្តិ និងសារាចរណែនាំនានា
- បន្តរៀបចំចាត់ចែងការងារនិងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រី-បុគ្គលិក ។

## ៥. ការងារប្រតិបត្តិការ

- សិក្សារៀបចំប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងមូលបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- បន្តរៀបចំបង្កើតសភាផាត់ទាត់នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាខេត្ត
- បន្តពង្រឹងការអនុវត្តប្រព័ន្ធផាត់ទាត់ក្នុងដំណាក់កាលមធ្យម (Interim Solution) ដើម្បីអនុវត្តកម្មវិធីផាត់ទាត់ដំណាក់កាលពេញលេញ (Full Solution) នាពេលខាងមុខ ។

## ៦. ការងារបោះផ្សាយ និងឃ្លាំងបេឡា

- បន្តពង្រឹងការងារបម្រើអតិថិជនក្នុងការបើកនិងបង់សាច់ប្រាក់នៅបញ្ជរបេឡាឱ្យបានលឿន និងកាន់តែប្រសើរឡើង
- បន្តណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ ដោយតាមដានជាប្រចាំនូវសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់របស់សាខាធនាគារជាតិនៃកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដើម្បីរាំងខ្ទប់ចរាចរណ៍ក្រដាសប្រាក់ក្លែងក្លាយ
- បង្កើនការប្រមូលក្រដាសប្រាក់ចាស់ៗដែលពិបាកធ្វើចរាចរណ៍ ដោយបញ្ចេញនូវក្រដាសប្រាក់ថ្មីជំនួសវិញ តាមប្រភេទឱ្យបានសមស្របទៅនឹងតម្រូវការទីផ្សារ
- បន្តពង្រឹងការងារដឹកជញ្ជូនធនបត្រ ។

## ៧. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- ចុះធ្វើសវនកម្មនៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត ខេត្តតាកែវ និងខេត្តក្រចេះ ព្រមទាំងចុះតាមដានការអនុវត្តតាមអនុសាសន៍នៅតាមសាខាធនាគារជាតិនៃកម្ពុជា ដែលបានចុះធ្វើសវនកម្មក្នុងឆ្នាំ ២០១០
- បន្តចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

## ៨. ការងារព័ត៌មានវិទ្យា

- ថែរក្សាប្រព័ន្ធធនាគារស្នូលទាំងនៅទីស្នាក់ការកណ្តាលនិងតាមបណ្តាសាខាខេត្តឲ្យមានដំណើរការរលូន
- បន្តអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាតិទូទាត់សងប្រាក់ ។

**៩. ការងារបណ្តុះបណ្តាល**

- ចូលរួមសហការ និងរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងប្រជុំផ្សេងៗនៅធនាគារជាតិនៃកម្ពុជា
- ចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា វគ្គសិក្សានានានៅក្នុងនិងក្រៅប្រទេស
- រៀបចំត្រៀមប្រឡងឆ្លងចូលក្របខ័ណ្ឌមន្ត្រីក្រមការ
- រៀបចំវគ្គសុក្រឹត្យការមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។

**១០. ទំនាក់ទំនងអន្តរជាតិ**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស៊ាសិន (SEACEN)
- បន្តពង្រឹងកិច្ចសហប្រតិបត្តិកាជាមួយអាស៊ាន
- បន្តពង្រឹងកិច្ចសហប្រតិបត្តិកាជាមួយប្រទេសក្នុងតំបន់ និងសកលលោក
- បន្តពង្រឹងកិច្ចសហប្រតិបត្តិកាជាមួយមូល និធិរូបិយវត្ថុអន្ត ជាតិ (IMF) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារទូទាត់អន្តរជាតិ (BIS) ។

# ឧបសម្ព័ន្ធ

# តារាង២ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រានិញចុងខែ)

| រូបិយប័ណ្ណនានា | ២០១០ | | | | | | | ២០១១ | | | | | | បម្រែបម្រួល% |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | មិថុនា-១១ /មិថុនា-១០ |
| អេសឌីអរ | ៦.២៥៣ | ៦.៤៥៤ | ៦.៤០៥ | ៦.៥៦៨ | ៦.៦២៥ | ៦.២៤៧ | ៦.២៤២ | ៦.៣៣៩ | ៦.៣៤០ | ៦.៣៣៥ | ៦.៥១៨ | ៦.៥០៦ | ៦.៥៧៩ | ៥,២១ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.៥៨៤ | ៣.៨១១ | ៣.៧៧៤ | ៤.០៩៧ | ៤.១១១ | ៣.៩១៩ | ៤.១១៤ | ៤.០០១ | ៤.០៩១ | ៤.១៣២ | ៤.៣៩៦ | ៤.៣៧៣ | ៤.៤០៦ | ២២,៩៤ |
| ដុល្លារ-ហុងកុង | ៥៤២ | ៥៤៥ | ៥៤៤ | ៥៤៥ | ៥៤៤ | ៥២៥ | ៥២១ | ៥២០ | ៥១៨ | ៥១៥ | ៥១៧ | ៥២៤ | ៥២៩ | -២,៤០ |
| យ៉េន-ជប៉ុន | ៤៧,៦៣ | ៤៨,៨២ | ៥០,០៨ | ៥០,៤៧ | ៥១,៧១ | ៤៨,៣៩ | ៤៩,៧០ | ៤៩,៣២ | ៤៩,៤២ | ៤៨,១៨ | ៤៩,២៦ | ៥០,៤៤ | ៥១,០០ | ៧,០៨ |
| វ៉ុន-កូរ៉េ | ៣,៤០ | ៣,៥៧ | ៣,៥៣ | ៣,៧០ | ៣,៧៤ | ៣,៥៣ | ៣,៥៩ | ៣,៦០ | ៣,៥៧ | ៣,៦៣ | ៣,៧៤ | ៣,៧៩ | ៣,៨៤ | ១២,៩៤ |
| ដុល្លារ-ញូស៊ីឡង់ | ២.៩២០ | ៣.០៦១ | ២.៩៧៣ | ៣.១១២ | ៣.១៥៨ | ៣.០៣៥ | ៣.១២៣ | ៣.១១៧ | ៣.០៣១ | ៣.០៥០ | ៣.២៣០ | ៣.៣៤២ | ៣.៤០៩ | ១៦,៧៥ |
| យ៉ន់ចិន | ៦២១ | ៦២៥ | ៦២៣ | ៦៣២ | ៦៣២ | ៦១២ | ៦១៣ | ៦១៥ | ៦១៤ | ៦១១ | ៦១៨ | ៦២៩ | ៦៣៧ | ២,៥៨ |
| ដុល្លារ-តៃវ៉ាន់ | ១៣១ | ១៣២ | ១៣២ | ១៣៥ | ១៣៧ | ១៣៤ | ១៣៩ | ១៤០ | ១៣៦ | ១៣៦ | ១៤០ | ១៤២ | ១៤២ | ៨,៤០ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រូពី-ឥណ្ឌូណេស៊ី | ០,៤៦ | ០,៤៧ | ០,៤៧ | ០,៤៧ | ០,៤៧ | ០,៤៥ | ០,៤៥ | ០,៤៥ | ០,៤៦ | ០,៤៦ | ០,៤៧ | ០,៤៨ | ០,៤៨ | ៣,២៤ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.២៩២ | ១.៣២៦ | ១.៣៤៥ | ១.៣៧០ | ១.៣៥៧ | ១.២៨៩ | ១.៣១៨ | ១.៣២២ | ១.៣២១ | ១.៣២៤ | ១.៣៥៤ | ១.៣៥៥ | ១.៣៦២ | ៥,៤២ |
| ប៉េសូ-ហ្វីលីពីន | ៩១,០៥ | ៩២,៧០ | ៩៣,៦៧ | ៩៥,៩៧ | ៩៧,៧៥ | ៩២,៣៦ | ៩២,៤៨ | ៩១,៨០ | ៩២,១៩ | ៩២,២៦ | ៩៣,៤៦ | ៩៤,១៩ | ៩៤,៦០ | ៣,៩០ |
| ដុល្លារ-សិង្ហបុរី | ៣.០០៧ | ៣.១០៦ | ៣.១២២ | ៣.២១០ | ៣.២៤១ | ៣.០៨៨ | ៣.១៤៣ | ៣.១៤៧ | ៣.១៦៤ | ៣.១៧៥ | ៣.២៧៧ | ៣.៣១១ | ៣.៣៣៩ | ១១,០៤ |
| បាត-ថៃ | ១៣០ | ១៣១ | ១៣៥ | ១៣៩ | ១៤១ | ១៣៥ | ១៣៤ | ១៣០ | ១៣២ | ១៣២ | ១៣៤ | ១៣៥ | ១៣៤ | ៣,០៨ |
| ដុង-វៀតណាម | ០,២២១ | ០,២២២ | ០,២១៧ | ០,២១៧ | ០,២១៧ | ០,២០៩ | ០,២០៨ | ០,២០៨ | ០,១៩៣ | ០,១៩២ | ០,១៩៦ | ០,១៩៨ | ០,២០០ | -៩,៥០ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.១៤២ | ៥.៥៣៣ | ៥.៣៥០ | ៥.៧៦១ | ៥.៨២០ | ៥.៣៤១ | ៥.៣៨៧ | ៥.៥០៤ | ៥.៥៣៧ | ៥.៦៥៧ | ៥.៩៦៨ | ៥.៨៤៧ | ៥.៩៥៥ | ១៥,៨១ |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.៣៥៣ | ៦.៦១១ | ៦.៥៤៦ | ៦.៦៨២ | ៦.៦៦១ | ៦.៣៤០ | ៦.២៥២ | ៦.៤១១ | ៦.៤៩៤ | ៦.៤៤០ | ៦.៦៩២ | ៦.៧៣១ | ៦.៦១២ | ៤,០៨ |

# ឧបសម្ព័ន្ធ ៣

## តារាង ៣ - ស្ថានភាពរូបិយវត្ថុ

(គិតជាពាន់លានរៀល)

| | ធ្នូ ២០១០ | ២០១១ | | | | | |
|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៦.៦៩៨** | **១៦.៩៥៨** | **១៧.១០៨** | **១៧.០៧៩** | **១៨.៣៨៩** | **១៨.២៩៦** | **១៨.០៧៦** |
| ទ្រព្យសកម្មបរទេស | ១៨.៩១៨ | ១៩.២៨៣ | ១៩.៤៨៩ | ១៩.៦២៤ | ២០.៨១១ | ២០.៨៤៥ | ២០.៦៤៤ |
| ទ្រព្យអកម្មបរទេស | -២.២២០ | -២.៣២៥ | -២.៣៨២ | -២.៥៤៤ | -២.៤២២ | -២.៥៤៩ | -២.៥៦៩ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **២.៧៧៩** | **២.៧២៦** | **២.៧៦២** | **៣.១៩៩** | **២.៦៧៩** | **៣.២៥៨** | **៣.៩១៨** |
| **ឥណទានក្នុងស្រុក** | **១១.២០៦** | **១១.២៥៤** | **១១.៤៨៦** | **១១.៦៥៨** | **១១.៨៤៦** | **១២.៣៣៧** | **១២.៤៦៩** |
| ឥណទានសុទ្ធទៅរដ្ឋាភិបាល | -២.១២៧ | -២.២៦៤ | -២.២១៩ | -២.២៥៣ | -២.៣១៣ | -២.៣៦២ | -២.៣២៥ |
| ឥណទានទៅរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -២.៣៩៧ | -២.៥៣៤ | -២.៤៨៩ | -២.៥២៣ | -២.៥៨៤ | -២.៦៣២ | -២.០៥៥ |
| ឥណទានទៅវិស័យមិនមែនរដ្ឋាភិបាល | ១៣.៣៣៣ | ១៣.៥១៧ | ១៣.៧០៤ | ១៣.៩១១ | ១៤.១៦០ | ១៤.៦៩៩ | ១៤.៧៩៥ |
| សហគ្រាសរដ្ឋ | ១,៧៧ | ១,៧៣ | ១,៦៩ | ១,៦៥ | ១,៦២ | ១,៦១ | ១,៦ |
| វិស័យឯកជន | ១៣.៣៣១ | ១៣.៥១៥ | ១៣.៧០៣ | ១៣.៩០៩ | ១៤.១៥៧ | ១៤.៦៩៧ | ១៤.៧៩៣ |
| ក្នុងនោះរូបិយប័ណ្ណបរទេស | ១២.៨៨៦ | ១៣.២៤២ | ១៣.៣០៩ | ១៣.៥១៥ | ១៣.៧៦៣ | ១៤.២៣០ | ១៤.០៥៣ |
| **ធាតុផ្សេងៗសុទ្ធ** | **-៨.៤២៨** | **-៨.៥២៨** | **-៨.៧២៤** | **-៨.៤៥៩** | **-៩.១៦៨** | **-៩.០៧៩** | **-៨៥៥១** |
| ប្រាក់បញ្ញើតម្កល់ | -៤៧៦ | -៤៩០ | -៤៩៣ | -៤៩៩ | -៥៣១ | -៥៤០ | -៥០៦ |
| មូលធននិងធនបម្រុង | -៨.៦៧៤ | -៨.៧២៩ | -៨.៨៧០ | -៨.៨៤៦ | -៩.២២៤ | -៩.៤០០ | -៩.០១១ |
| ផ្សេងៗ | ៧២២ | ៦៩១ | ៦៣៩ | ៨៨៦ | ៥៨៧ | ៨៦២ | ៩៦៦ |
| **រូបិយវត្ថុទូលំទូលាយ (M2)** | **១៩.៤៧៧** | **១៩.៦៨៤** | **១៩.៨៧០** | **២០.២៧៨** | **២១.០៦៨** | **២១.៥៥៤** | **២១.៩៩៤** |
| **រូបិយវត្ថុ (M1)** | **៣.២២១** | **៣.២១៧** | **៣.៣៤៧** | **៣.៤៩៧** | **៣.៦១៨** | **៣.៥៥៣** | **៣.៦៥៧** |
| រូបិយវត្ថុក្រៅធនាគារ | ៣.០៩៩ | ៣.០៨១ | ៣.១៨៣ | ៣.៣៨៣ | ៣.៤៨៧ | ៣.៣៨៨ | ៣.៥២៣ |
| ប្រាក់បញ្ញើចរន្ត | ១២២ | ១៣៥ | ១៦៤ | ១១៥ | ១៣០ | ១៦៥ | ១៣៤ |
| **រូបិយវត្ថុផ្សេងៗ** | **១៦.២៥៦** | **១៦.៤៦៨** | **១៦.៥២២** | **១៦.៧៨១** | **១៧.៤៤៥** | **១៨.០០០** | **១៨.៣៣៧** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៤០៨ | ៣៨៩ | ៤៤០ | ៣៩២ | ៤០១ | ៤២៨ | ៤២៨ |
| ប្រាក់បញ្ញើរូបិយប័ណ្ណ | ១៥.៨៤៨ | ១៦.០៧៨ | ១៦.០៨២ | ១៦.៣៩០ | ១៧.០៤៨ | ១៧.៥៧២ | ១៧.៩០៩ |
| **អនុស្សរណៈ** | | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** (ជាលានដុល្លារ) | **៤.១២០** | **៤.១៨៥** | **៤.២៣៦** | **៤.២៥៩** | **៤.៥៧០** | **៤.៤៨០** | |
| ធនាគារជាតិនៃកម្ពុជា | ៣.៦៩៧ | ៣.៦៥៦ | ៣.៧៣៦ | ៣.៧៥៤ | ៣.៩៤២ | ៣.៩៥៨ | |
| ធនាគារពាណិជ្ជ | ៤២៣ | ៥២៩ | ៥០០ | ៥០៥ | ៦២៨ | ៥២២ | |
| **ល្បឿនចរាចររូបិយវត្ថុ** | **១៣,៥** | **១៣,៥** | **១៤,៥** | **១៥,៥** | **១៥,៥** | **១៥,៥** | |

# ឧបសម្ព័ន្ធ ៤

## តារាង ៤ - ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ-១០ | មករា-១១ | កុម្ភៈ-១១ | មីនា-១១ | មេសា-១១ | ឧសភា-១១ | មិថុនា-១១ |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១,៤** | **១,៦** | **០,៩** | **-០,២** | **៧,៧** | **-០,៥** | **-១,២** |
| ទ្រព្យសកម្មបរទេស | -០,៣ | ១,៩ | ១,១ | ០,៧ | ៦.១ | ០,២ | -១,៨ |
| ទ្រព្យអកម្មបរទេស | ៩,៥ | ៤,៨ | ២,៤ | ៦,៨ | -៤,៨ | ៥,២ | ០,៩ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **២៨,៣** | **-១,៩** | **១,៣** | **១៥,៨** | **-១៦,៣** | **២១,៦** | **២០,៣** |
| **ឥណទានក្នុងស្រុក** | **៧,០** | **០,៤** | **២,១** | **១,៥** | **១,៦** | **៤,១** | **១,១** |
| **ឥណទានសុទ្ធទៅរាជរដ្ឋាភិបាល** | **៣,៣** | **-៦,៤** | **២,០** | **-១,៥** | **-២,៧** | **-២,១** | **-១,៦** |
| ឥណទានទៅរាជរដ្ឋាភិបាល | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៣,០ | ៥,៧ | -១,៨ | ១,៤ | ២,៤ | ១,៩ | ២,១ |
| **ឥណទានទៅផ្នែកមិនមែនរាជរដ្ឋាភិបាល** | **៥,២** | **១,៤** | **១,៤** | **១,៥** | **១,៨** | **៣,៨** | **០,៧** |
| សហគ្រាសរដ្ឋ | -២,៥ | -១,៩ | -២,៤ | -២,៦ | -១,៧ | -០,៦ | ២,៤ |
| ផ្នែកឯកជន | ៥,២ | ១,៤ | ១,៤ | ១,៥ | ១,៨ | ៣,៨ | ០,៦ |
| ក្នុងនោះ-រូបិយប័ណ្ណបរទេស | ៥,១ | ២,៨ | ០,៥ | ១,៥ | ១,៨ | ៣,៤ | -១,២ |
| **ធាតុផ្សេងៗសុទ្ធ** | **-១,៤** | **-១,២** | **-២,៣** | **៣,០** | **-៨,៤** | **១,០** | **៥,៨** |
| ប្រាក់បញ្ញើមូលប័ត្រ | -១៦,៦ | -២,៨ | -១៦,៦ | ១,១ | ៦,៥ | ១,៧ | ៦,២ |
| មូលធននិងធនបម្រុង | ១,០ | ០,៦ | ១,៦ | -០,៣ | ៤,៣ | ១,៩ | ៤,១ |
| ផ្សេងៗ | -២,៧ | -៤,៣ | -៧,៥ | ៣៨,៧ | -៣៣,៧ | ៤៦,៧ | ១២,២ |
| **រូបិយវត្ថុទូលំទូលាយ (M2)** | **១,៩** | **១,១** | **០,៩** | **២,១** | **៣,៩** | **២,៣** | **២,០** |
| **រូបិយវត្ថុ (M1)** | **៥,១** | **-០,១** | **៤,១** | **៤,៥** | **៣,៤** | **-១,៨** | **២,៩** |
| រូបិយវត្ថុក្រៅធនាគារ | ៦,២ | -០,៦ | ៣,៣ | ៦,៣ | ៣,១ | -២,៩ | ៤,០ |
| ប្រាក់បញ្ញើចរន្ត | -១៥,៩ | ១០,៧ | ២១,៣ | -៣០,៣ | ១៣,៨ | ២៧ | -១៨,៨ |
| **រូបិយវត្ថុផ្សេងៗ** | **១,៣** | **១,៣** | **០,៣** | **១,៦** | **៤,០** | **៣,២** | **១,៩** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១,៧ | -៤,៦ | ១៣,១ | -១១,១ | **២,៥** | **៦,៦** | **០,០** |
| ប្រាក់បញ្ញើរូបិយប័ណ្ណ | ១,៣ | ១,៥ | ០,០២ | ១,៩ | ៤,០ | ៣,១ | ១,៩ |
| **អនុស្សរណៈ** | | | | | | | |
| **ទ្រព្យសកម្មបរទេស (គិតជាលានដុល្លារ)** | **៣៣,៧** | **១,៦** | **១,២** | **០,៦** | **៧,៣** | **-២,០** | |
| ធនាគារជាតិនៃកម្ពុជា | ៣១,០ | -១,១ | ២,២ | ០,៥ | ៥,០ | **០,៤** | |
| ធនាគារពាណិជ្ជ | ៤៥,៦ | ២៤,៩ | ៥៥,៥ | ១,៦ | ២៤,២ | -១៦,៩ | |
| **ល្បឿនរង្វិលរូបិយវត្ថុ** | **-៩,៩** | **០,០** | **៧,៤** | **៦,៩** | **០,០** | **០,០** | |

# ឧបសម្ព័ន្ធ ៥

## តារាង ៥ - តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ ២០១០ | ២០១១ មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|---|
| **គិតជាពាន់លានរៀល** | | | | | | | |
| **រូបិយវត្ថុបម្រុង** | **១០.២៤៥** | **១០.០០៤** | **១០.១៥៦** | **១០.១០៧** | **១០.៦១៧** | **១០,៧៩៣** | **១០.៨៣០** |
| **រូបិយវត្ថុក្រៅធនាគារ** | **៣.០៩៩** | **៣.០៨១** | **៣.១៨៣** | **៣.៣៨៣** | **៣.៤៨៧** | **៣.៣៨៨** | **៣.៥២៣** |
| **សាច់ប្រាក់ក្នុងធនាគារពាណិជ្ជ** | **១៤០** | **១៥៧** | **១៦០** | **១៣៩** | **១៤៥** | **១៦៩** | **១៤១** |
| **ប្រាក់បញ្ញើធនាគារ** | **៦.៩៧៨** | **៦.៧២២** | **៦.៧៥៣** | **៦.៥៥៩** | **៦.៩៥៨** | **៧.១៩១** | **៧.១២៦** |
| ប្រាក់បម្រុងកាតព្វកិច្ច | ២.១៣៤ | ២.១៨១ | ២.២២៩ | ២.២៥១ | ២.៣២២ | ២.៣៩៣ | ២.៣៤៣ |
| ប្រាក់បញ្ញើផ្សេងៗ | ៤.៨៤៤ | ៤.៥៤១ | ៤.៥២៤ | ៤.៣០៨ | ៤.៦៣៧ | ៤.៧៩៩ | ៤.៧៨៤ |
| **ផ្សេងៗ** | **២៨** | **៤៤** | **៦០** | **២៦** | **២៦** | **៤៥** | **៤០** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៤.៩៨២** | **១៤.៨១៥** | **១៥.០៨៨** | **១៥.០៥២** | **១៥.៨៦២** | **១៦.១៦៤** | **១៥.៩៩៩** |
| ទ្រព្យសកម្មបរទេស | ១៥.៤១០ | ១៥.២៤៨ | ១៥.៥២៣ | ១៥.៤៨៨ | ១៦.៣០៩ | ១៦.៦១២ | ១៦.៤៤៦ |
| ទ្រព្យអកម្មបរទេស | ៤២៧ | ៤៣៣ | ៤៣៥ | ៤៣៥ | ៤៤៧ | ៤៤៧ | ៤៥៥ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៤.៧៣៨** | **-៤.៨១១** | **-៤.៩៣២** | **-៤.៩៤៥** | **-៥.២៤៥** | **-៥.៣៧១** | **-៥.១៧០** |
| **ឥណទានសុទ្ធទៅលើរដ្ឋាភិបាល** | **-១.៧៨៥** | **-១.៩០២** | **-១.៨៧៥** | **-១.៩១០** | **-១.៩២២** | **-១.៩៤២** | **-១.៩៩៣** |
| ឥណទានទៅរដ្ឋាភិបាល | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -២.០៥៥ | ២.១៧២ | ២.១៤៥ | ២.១៨១ | ២.១៩២ | ២.២១២ | ២.២៦៣ |
| **ឥណទានសុទ្ធទៅលើធនាគារពាណិជ្ជ** | **-៤៣៩** | **-៤៣៧** | **-៤៥៧** | **-៤៥៣** | **-៤៤៤** | **-៤៧៧** | **-៤៤៩** |
| **ឥណទានទៅលើសហគ្រាសឯកជន** | **0** | **0** | **0** | **0** | **0** | **0** | **0** |
| **ធាតុផ្សេងៗសុទ្ធ** | **-២.៥១៤** | **-២.៤៧២** | **-២.៦០១** | **-២.៥៨២** | **-២.៨៨០** | **-២.៩៥២** | **-២.៧២៨** |
| **បម្រែបម្រួលជាភាគរយ** | | | | | | | |
| **រូបិយវត្ថុបម្រុង** | **-០,២** | **-២,៣** | **១,៥** | **-០,៥** | **៥,០** | **១,៧** | **០,៣** |
| **រូបិយវត្ថុក្រៅធនាគារ** | **៦,២** | **-០,៦** | **៣,៣** | **៦,៣** | **៣,១** | **-២,៩** | **៤,០** |
| **សាច់ប្រាក់ក្នុងធនាគារពាណិជ្ជ** | **៩,៧** | **១១,៦** | **២,១** | **-១៣,១** | **៤,២** | **១៦,៧** | **-១៦,៦** |
| **ប្រាក់បញ្ញើធនាគារ** | **-២,៩** | **-៣,៧** | **០,៥** | **-២,៩** | **៦,១** | **៣,៣** | **-០,៩** |
| ប្រាក់បម្រុងកាតព្វកិច្ច | ០,៨ | ២,២ | ២,២ | ១,០ | ៣,១ | ៣,១ | -២,១ |
| ប្រាក់បញ្ញើផ្សេងៗ | -៤,៤ | -៦,៣ | -០,៤ | -៤,៨ | ៧,៦ | ៣,៥ | -០,៣ |
| **ផ្សេងៗ** | **-២៦,១** | **៦០,១** | **៣៥,៤** | **-៥៧,៣** | **២,២** | **៧១,៣** | **-១០,៩** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-០,១** | **-១,១** | **១,៨** | **-០,២** | **៥,៤** | **១,៩** | **-១,០** |
| ទ្រព្យសកម្មបរទេស | -០,១ | -១,០ | ១,៨ | -០,២ | ៥,៣ | ១,៩ | -១,០ |
| ទ្រព្យអកម្មបរទេស | ០,៣ | ១,៤ | ០,៤ | ០,១ | ២,៦ | ០,២ | -១,៨ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-០,២** | **-១,៥** | **-២,៥** | **-០,៣** | **-៦,៤** | **-២,៤** | **៣,៧** |
| **ឥណទានសុទ្ធទៅលើរដ្ឋាភិបាល** | **១,៨** | **-៦,៦** | **១,៤** | **-១,៩** | **-០,៦** | **-១,១** | **-២៦** |
| ឥណទានទៅរដ្ឋាភិបាល | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -១,៦ | ៥,៧ | -១,២ | ១,៧ | ០,៥ | ០,៩ | ២,៣ |
| **ឥណទានសុទ្ធទៅលើធនាគារពាណិជ្ជ** | **៥,២** | **-០,៥** | **៤,៦** | **-០,៩** | **-២,០** | **៧.៤** | **-៥,៩** |
| **ឥណទានទៅលើសហគ្រាសឯកជន** | **០,០** | **០,០** | **០,០** | **០,០** | **០,០** | **០,០** | **០,០** |
| **ធាតុផ្សេងៗសុទ្ធ** | **០,៨** | **-១,៧** | **៥,២** | **-០,៧** | **១១,៥** | **២,៥** | **-២១,៩** |

# ឧបសម្ព័ន្ធ ៦

## តារាង ៦ - តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-១០ | មករា-១១ | កុម្ភៈ-១១ | មីនា-១១ | មេសា-១១ | ឧសភា-១១ | មិថុនា-១១ |
|---|---|---|---|---|---|---|---|
| **គិតជាពាន់លានរៀល** | | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១.៧១៥** | **២.១៤៣** | **២.០១៩** | **២.០២៧** | **២.៥២៧** | **២.១៣២** | **២.០៧៦** |
| ទ្រព្យសកម្មបរទេស | ៣.៥០៨ | ៤.០៣៥ | ៣.៩៦៦ | ៤.១៣៦ | ៤.៥០២ | ៤.២៣៣ | ៤.១៩៨ |
| ទ្រព្យអកម្មបរទេស | -១.៧៩២ | ១.៨៩២ | ១.៩៤៦ | ២.១០៩ | ១.៩៧៥ | ២.១០១ | ២.១២២ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៧.១៨៥** | **៧.១៨៦** | **៧.៣១៨** | **៧.៧០៣** | **៧.៥៩១** | **៨.១៤៧** | **៨.៨៩៥** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **១២.៩៩១** | **១៣.១៥៥** | **១៣.៣៦១** | **១៣.៥៦១** | **១៣.៧៤៩** | **១៤.២៥៩** | **១៤,៤៥៥** |
| ឥណទានសុទ្ធទៅលើរាជរដ្ឋាភិបាល | -៣៤២ | -៣៦២ | -៣៤៤ | -៣៤២ | -៣៩១ | -៤២០ | -៣៣២ |
| ឥណទានទៅលើសហគ្រាសរដ្ឋ | ២ | ២ | ២ | ២ | ២ | ២ | ២ |
| ឥណទានទៅលើវិស័យឯកជន | ១៣.៣៣១ | ១៣.៥១៥ | ១៣.៧០៣ | ១៣.៩០៩ | ១៤.១៥៨ | ១៤.៦៩៧ | ១៤.៧៩៣ |
| ឥណទានសុទ្ធទៅលើធនាគារជាតិនៃកម្ពុជា | ០ | ០ | ០ | -៨ | -២០ | -២០ | -៨ |
| **ធាតុផ្សេងៗសុទ្ធ** | **-៥.៨០៦** | **-៥.៩៦៩** | **-៦.០៤២** | **-៥.៨៥៧** | **-៦.១៥៨** | **-៦.១១៣** | **-៥.៥៦០** |
| **ទុនបម្រុង** | **៧.៤៥០** | **៧.២៣០** | **៧.២៨៩** | **៧.១៤០** | **៧.៤៣៦** | **៧.៨៤២** | **៧.៤៦០** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ១៤០ | ១៥៧ | ១៦០ | ១៣៩ | ១៤៥ | ១៦៩ | ១៣៩ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ៧.៣០៩ | ៧.០៧៣ | ៧.១២៩ | ៧.០០១ | ៧.២៩១ | ៧.៦៧៣ | ៧.៣២១ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **១៦.៣៥១** | **១៦.៥៥៩** | **១៦.៦២៧** | **១៦.៨៧០** | **១៧.៥៥៤** | **១៨.១២១** | **១៨.៤៣២** |
| ប្រាក់បញ្ញើចរន្ត | ៩៥ | ៩១ | ១០៤ | ៨៩ | ១០៤ | ១២១ | ៩៤ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៤០៨ | ៣៨៩ | ៤៤០ | ៣៩២ | ៤០២ | ៤២៨ | ៤២៨ |
| ប្រាក់បញ្ញើរូបិយប័ណ្ណ | ១៥.៨៤៨ | ១៦.០៧៨ | ១៦.០៨២ | ១៦.៣៩០ | ១៧.០៤៩ | ១៧.៥៧៣ | ១៧.៩០៩ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **២៦.៣៧២** | **២៦.៨៣០** | **២៧.០៣៤** | **២៧.៣៦៨** | **២៨.៤៣៦** | **២៩.០៩២** | **២៨.៦៤៧** |
| **បម្រែបម្រួលប្រចាំខែជាភាគរយ** | | | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **-១១,៨** | **២៥,០** | **-៥,៨** | **០,៤** | **២៤,៧** | **-១៥,៦** | **-២,៦** |
| ទ្រព្យសកម្មបរទេស | -១,០ | ១៥,០ | -១,៧ | ៤,៣ | ៨,៨ | -៦,០ | -០,៨ |
| ទ្រព្យអកម្មបរទេស | -១១,៩ | -២០៥,៦ | ២,៩ | ៨,៤ | -៦,៤ | ៦,៤ | ១,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៨,៩** | **០,០** | **១,៨** | **៥,៣** | **-១,៥** | **៧,៣** | **៩,២** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៥,៧** | **១,៣** | **១,៦** | **១,៥** | **១,៤** | **៣,៧** | **១,៤** |
| ឥណទានសុទ្ធទៅលើរាជរដ្ឋាភិបាល | -១០,៧ | ៥,៨ | -៥,០ | -០,៦ | ១៤,៣ | ៧,៤ | -២១,០ |
| ឥណទានទៅលើសហគ្រាសរដ្ឋ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ឥណទានទៅលើវិស័យឯកជន | ៥,២ | ១,៤ | ១,៤ | ១,៥ | ១,៨ | ៣,៨ | ០,៧ |
| ឥណទានសុទ្ធទៅលើធនាគារជាតិនៃកម្ពុជា | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| **ធាតុផ្សេងៗសុទ្ធ** | **-១,៩** | **-២,៨** | **-១,២** | **៣,១** | **-៥,១** | **០,៧** | **៩,០** |
| **ទុនបម្រុង** | **-២,១** | **-៣,០** | **០,៨** | **-២,០** | **៤,១** | **៥,៥** | **-៤,៩** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៩,៤ | ១២,១ | ១,៩ | -១៣,១ | ៤,៣ | ១៦,៦ | -១៧,៨ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | -២,៣ | -៣,២ | ០,៨ | -១,៨ | ៤,១ | ៥,២ | -៤,៦ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុកសុទ្ធ)** | **១,២** | **១,៣** | **០,៤** | **១,៥** | **៤,១** | **៣,២** | **១,៧** |
| ប្រាក់បញ្ញើចរន្ត | -១២,០ | -៤,២ | ១៤,៣ | -១៤,៤ | ១៦,៩ | ១៦,៣ | -២២,៣ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ១,៦ | -៤,៧ | ១៣,១ | -១០,៩ | ២,៦ | ៦,៥ | ០,០ |
| ប្រាក់បញ្ញើរូបិយប័ណ្ណ | ១,៣ | ១,៥ | ០,០ | ១,៩ | ៤,០ | ៣,១ | ១,៩ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **២,៥** | **១,៧** | **០,៨** | **១,២** | **៣,៩** | **២,៣** | **-១,៥** |

# ឧបសម្ព័ន្ធ ៧

## តារាង ៧ - ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច

(ឯកតា : ពាន់លានរៀល)

| | ធ្នូ-១០ | មករា-១១ | កុម្ភៈ-១១ | មីនា-១១ | មេសា-១១ | ឧសភា-១១ | មិថុនា-១១ |
|---|---|---|---|---|---|---|---|
| **១- គ្រឹះស្ថានហិរញ្ញវត្ថុ** | **១៧៧** | **១៨២** | **១៦៥** | **១៨០** | **១៨១** | **១៨៦** | |
| ធនាគារជាតិនៃកម្ពុជា | ០ | ០ | ០ | ០ | ០ | ០ | |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ១៨ | ២៤ | ២៥ | ៣១ | ៣៥ | ៣០ | |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១៦០ | ១៥៨ | ១៤០ | ១៤៩ | ១៤៦ | ១៥៦ | |
| **២- គ្រឹះស្ថានមិនបម្រើឲ្យហិរញ្ញវត្ថុ** | **១១.៦៩៥** | **១១.៨៩៤** | **១២.០៥៨** | **១២.២១២** | **១២.៤០១** | **១២.២២២** | |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៨៨៤ | ៩២៤ | ៩៥២ | ១.០០២ | ១.០៣៩ | ១.០០៥ | |
| ឧស្សាហកម្មរ៉ែ | ៥៥ | ៥៥ | ៥៦ | ៥៩ | ៥៩ | ៥៩ | |
| កម្មន្តសាល | ១.១៥០ | ១.១៩៤ | ១.២២៩ | ១.២៥០ | ១.២៨៤ | ១.២៥០ | |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ៧៣ | ៦៧ | ៧១ | ១១៣ | ១០៦ | ១១៣ | |
| សំណង់ | ៩៣១ | ៩៤៨ | ៩៦៧ | ៩៤៧ | ៩៦៨ | ៩៤២ | |
| ការជួញដូរដុំ | ២.៣១៦ | ២.៣៧៤ | ២.៤៣៩ | ២.៤៥១ | ២.៤៨៣ | ២.៤៦៤ | |
| ការជួញដូររាយ | ២.៣៧០ | ២.៣២៨ | ២.៣៥៤ | ២.៤០០ | ២.៤០៩ | ២.៤០៣ | |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ១.២៨៨ | ១.២៨៦ | ១.២៥៤ | ១.២៣៨ | ១.២៥៨ | ១.២៣៨ | |
| ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន | ២៥២ | ២៦១ | ២៥៥ | ២៥៧ | ២៦៣ | ២៥៧ | |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ៣៥៦ | ៣៨៥ | ៣៨៤ | ៣៨២ | ៣៧៧ | ៣៨២ | |
| អាជីវកម្មជួល ភតិសន្យាហិរញ្ញវត្ថុ មិនរាប់បញ្ចូលភតិសន្យានិងការជួលអចលនទ្រព្យ | ៩៩ | ១១២ | ១១៥ | ១២៨ | ១៤១ | ១២៨ | |
| ការជួញដូរអចលនទ្រព្យ | ៦១៣ | ៦០៣ | ៦២១ | ៦២១ | ៦២៩ | ៦២១ | |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត | ១.៣០៩ | ១.៣៥៨ | ១.៣៦១ | ១.៣៦៦ | ១.៣៨៦ | ១.៣៦២ | |
| **៣- គម្រោងការផ្ទាល់ខ្លួនផ្សេងៗទៀត** | **១.១៨៣** | **១.២០៧** | **១.២២៨** | **១.២៥៨** | **១.៣១២** | **១.២៥៨** | |
| ការប្រើប្រាស់បុគ្គល | ៦៨៤ | ៦៨៣ | ៦៨៦ | ៦៨១ | ៦៩៨ | ៦៨១ | |
| ការប្រើប្រាស់កាតឥណទាន | ២៤ | ២៥ | ២២ | ២២ | ២៥ | ២២ | |
| ការប្រើប្រាស់ទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន | ៤៧៦ | ៤៩៨ | ៥២១ | ៥៥៥ | ៥៨៩ | ៥៥៥ | |
| **៤- ឥណទានផ្សេងៗ** | **១៦៦** | **១៦៨** | **១៨៤** | **១៩១** | **២០២** | **១៩១** | |
| **សរុបឥណទានផ្តល់** | **១៣.២២១** | **១៣.៤៥១** | **១៣.៦៣៥** | **១៣.៨៤១** | **១៤.០៩៦** | **១៣.៨៥៧** | |

## តារាង ៨ - សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(ឯកតា : ពាន់លានរៀល)

| | ធ្នូ-១០ | មករា-១១ | កុម្ភៈ-១១ | មីនា-១១ | មេសា-១១ | ឧសភា-១១ | មិថុនា-១១ |
|---|---|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | | | |
| ប្រាក់បញ្ញើចរន្ត | ១៤១ | ១៧២ | ១៧០ | ១៥២ | ១៧៨ | | |
| ប្រាក់បញ្ញើសន្សំ | ១៩៨ | ១៩១ | ២៣៥ | ១៨១ | ១៩២ | | |
| ប្រាក់បញ្ញើមានកាលកំណត់ | ២០១ | ១៩០ | ១៩២ | ១៩៥ | ១៩៥ | | |
| ប្រាក់បញ្ញើផ្សេងៗ | ១ | ១ | ១ | ១ | ១ | | |
| **សរុប** | **៥៤១** | **៥៥៥** | **៥៩៩** | **៥៣០** | **៥៦៦** | | |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស** | | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៣.២១៩ | ៣.២៦០ | ៣.១៧៩ | ៣.២៧៨ | ៦.៥២២ | | |
| ប្រាក់បញ្ញើសន្សំ | ៦.០៧៤ | ៦.១៣៧ | ៦.២៤៨ | ៦.៤០៦ | ៦.៥២២ | | |
| ប្រាក់បញ្ញើមានកាលកំណត់ | ៧.៥៦៥ | ៧.៧១០ | ៧.៥៧៦ | ៧.៧២៤ | ៧.៩៧០ | | |
| ប្រាក់បញ្ញើផ្សេងៗ | ៨០ | ៩៥ | ១៤៤ | ៨៧ | ១០២ | | |
| **សរុប** | **១៦.៩៣៨** | **១៧.២០០** | **១៧.១៤៧** | **១៧.៤៩៥** | **១៨.២៣០** | | |
| **សរុបរួម** | **១៧.៤៧៩** | **១៧.៧៥៥** | **១៧.៧៤៦** | **១៨.០២៥** | **១៨.៧៩៦** | | |

# ឧបសម្ព័ន្ធ ៨

## តុល្យការទូទាត់របស់កម្ពុជា

ឆ្នាំ២០០៨ ដល់ ឆមាសទី១ ឆ្នាំ២០១១

(គិតជាលានដុល្លារអាមេរិក)

| | ២០០៨ | ២០០៩ | ២០១០ | | ២០១១[ព] |
|---|---|---|---|---|---|
| | | | ឆមាសទី១ | ឆមាសទី២ | ឆមាសទី១ |
| **ជញ្ជីងពាណិជ្ជកម្ម** | **-១.៨០០,៤** | **-១.៦៣៤,២** | **-៨៨៩,១** | **-៨២៥,៨** | **-៩៤០,៨** |
| នាំចេញ (FOB) | ៤.៧០៨,០ | ៤.១៩៦,២ | ២.៥៥៥,០ | ២.៥១៣,០ | ២.៧២៤,១ |
| នាំចេញផលិតផលក្នុងស្រុក | ៤.៤២៣,៧ | ៣.៨៧៩,៤ | ២.៣៩៦,៨ | ២.៣៥០,៤ | ២.៥៥៨,៩ |
| នាំចេញតាមប្រព័ន្ធ GSP (ភាគច្រើនសម្លៀកបំពាក់) | ៣.០០៦,៤ | ២.៥១៤,៨ | ១.៣៤៨,០ | ១.៨៦០,៩ | ១.៧៣២,២ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ១.៤១៧.៣ | ១.៣៦៤,៦ | ១.០៤៨,៧ | ៤៨៩,៥ | ៨២៦,៦ |
| នាំចេញបន្ត (រាប់បញ្ចូលចំណេញ និងចំណាយដឹកជញ្ជូន) | ២៨៤,៣ | ៣១៦,៨ | ១៥៨,២ | ១៦២,៦ | ១៦៥,២ |
| នាំចូល (FOB) | -៦.៥០៨,៤ | -៥.៨៣០,៥ | -៣.៤៤៤,១ | -៣.៣៣៨,៨ | -៣.៦៦៤,៩ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៦.២៧១,០ | -៥.៥៦៥,៤ | -៣.៣១១,១ | -៣.២០២,១ | -៣.៥៣០,០ |
| សម្លៀកបំពាក់ | -១.៤០៤,១ | -១.១៩១,៨ | -៦៣៦,៨ | -៨៨១,៤ | -៦៨៥,២ |
| ប្រេងឥន្ធនៈ | -១.៩២៤,៣ | -១.៨០៥,៤ | -១.២៤២,៩ | -៧៤៩,៣ | -១.៣៣៦,៥ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -២.៩៤២,៦ | -២.៥៦៨,១ | -១.៤៣១,៥ | -១.៥៧១,៤ | -១.៥០៨,២ |
| នាំចូលសម្រាប់នាំចេញបន្ត | -២៣៧,៤ | -២៦៥,១ | -១៣២,៩ | -១៣៦,៧ | -១៣៤,៩ |
| **សេវា (សុទ្ធ)** | **៦០៩,៤** | **៦០៦,៤** | **៣៤៥,៣** | **៣១៧,៤** | **៣៧១,៣** |
| ចំណូល | ១.៦៤៥,១ | ១.៦២៤,៩ | ៨៦៣,៨ | ៨៨០,១ | ៩៤១,២ |
| ក្នុងនោះ : សេវាទេសចរណ៍ | ១.២១៨,៨ | ១.១៨៤,៦ | ៦២២,៧ | ៦៣៧,៣ | ៦៩២,៨ |
| ចំណាយ | -១.០៣៥,៨ | -១.០១៨,៤ | -៥១៨,៦ | -៥៦២,៧ | -៥៦៩,៩ |
| ក្នុងនោះ : សេវាទេសចរណ៍ | -៩៦,៨ | -១០៣,៥ | -៩១,៧ | -១០៦,០ | -៩៩,១ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-៤៧៤,៦** | **-៤៧៧,២** | **-២៦៣,០** | **-៣១៣,៥** | **-៣៣២,៩** |
| ចំណូល | ១០៨,៤ | ៥៥,៦ | ២៥,១ | ២៨,៦ | ២៧,១ |
| ក្នុងនោះ : ការប្រាក់ | ៦២,៦ | ២៦,២ | ១០,៣ | ១៣,៦ | ១២,០ |
| ចំណាយ | -៥៨៣,០ | -៥៣២,៨ | -២៨៨,០ | -៣៤២,១ | -៣៦០,០ |
| ក្នុងនោះ : - ការបង់ការប្រាក់ | -៤៦,៥ | -៤៨,៨ | -២៥,១ | -២៦,៩ | -២៧,៦ |
| - ចំណូលពីហ៊ុន | -៣៨៩,៩ | -៣៤៤,២ | -១៦៨,៨ | -២១៥,៦ | -២៣៤,៥ |
| **ផ្ទេរឯកជន (សុទ្ធ)** | **២៨៤,៣** | **២៩៣,១** | **១០១,៥** | **១៤៤,៤** | **១២៦,៦** |
| ចំណូល | ៣៧១,៨ | ៣៧០,៤ | ១៥៥,៥ | ១៩៨,៩ | ១៨២,៥ |
| ចំណាយ | ៨៧,៤ | ៧៧,២ | ៥៤,០ | ៥៤,៥ | ៥៥,៩ |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលផ្ទេរផ្លូវការ) | **-១.៣៨១,៣** | **-១.២១១,៩** | **-៧០៥,២** | **-៦៧៧,៤** | **-៧៧៥,៨** |
| **ផ្ទេរផ្លូវការ (សុទ្ធ)** | **៥៦៣,៣** | **៥៩២,៦** | **៣៨៧,៥** | **៤១២,២** | **៤៣០,០** |
| ចំណូល | ៥៦៣,៦ | ៥៩២,៩ | ៣៨៧,៦ | ៤១២,៤ | ៤៣០,០ |
| ចំណាយ | -០,៣ | -០,៣ | -០,១ | -០,១ | -- |
| **សមតុល្យគណនីចរន្តនិងផ្ទេរដើមទុន** | **-៦១៨,០** | **-៦១៩,៣** | **-៣១៧,៧** | **-២៦៥,២** | **-៣៤៥,៨** |
| **គណនីហិរញ្ញវត្ថុ** | **១.៣៨៦,៣** | **៦០៨,៣** | **៤៧១,៥** | **៣១៦,៦** | **៤៩០,៩** |
| **ឥណទានរយៈពេលវែងផ្លូវការ** (មិនរាប់បញ្ចូល IMF) **សុទ្ធ** | ២៣៤,៧ | ១៥៣,១ | ១៧៦,០ | ៦៨,៩ | ១៣៤,៧ |
| ដកប្រាក់ | ២២៤,៩ | ១៦៤,១ | ១៧៩,៦ | ៧៧,៥ | ១៤១,៤ |
| ទូទាត់ | -១០,២ | -១១,០ | -៣,៦ | -៨,៦ | -៦,៧ |
| **វិនិយោគមិនផ្លូវការ** | **១.១៥១,៧** | **៤៥៥,២** | **២៩៥,៤** | **២៤៧,៧** | **៣៥៦,២** |
| វិនិយោគផ្ទាល់ (សុទ្ធ) * | ៧៩៤,៧ | ៥២០,៣ | ២៩៨,១ | ៤៧១,៣ | ៣៧៥,០ |
| វិនិយោគលើផលប័ត្រ (សុទ្ធ) * | -១១,៦ | -៧,៦ | -៣,៧ | -៣,៩ | -៣,៨ |
| វិនិយោគផ្សេងទៀត (សុទ្ធ) * | ៣៦៨,៦ | -៥៧,៥ | ១,១ | -២១៩,៨ | -១៥,០ |
| **កំហុស និងចំលង** | **-៤៦,៣** | **៦,៣** | **-៨៣,៥** | **២៨,៧** | **-៣៤,៨** |
| **សមតុល្យរួម** | **៥២២,០** | **-៤,៧** | **៧០,២** | **៨០,០** | **១១០,៣** |
| **ហិរញ្ញប្បទាន** | **-៥២២,០** | **៤,៧** | **-៧០,២** | **-៨០,០** | **-១១០,៣** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៥៣៤,៨ | -៨,១ | -៧៣,៣ | -៨៩,៧ | -១១០,៣ |
| បម្រែបម្រួលទ្រព្យសកម្មទុនបម្រុងបរទេស | -៥៣៤,៨ | -១១៦,៦ | -៧៣,៣ | -៨៩,៧ | -១១០,៣ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -- | -- | -- | -- | -- |
| ការបែងចែក SDR | -- | ១០៨,៥ | -- | -- | -- |
| ហិរញ្ញប្បទានពិសេស | ១២,៨ | ១២,៨ | ៣,១ | ៩,៧ | -- |

** តម្លៃវិជ្ជមាន តំណាងឲ្យការថយចុះទ្រព្យសកម្មបរទេស ឬការកើនឡើងទ្រព្យអកម្មបរទេស និងតម្លៃអវិជ្ជមាន តំណាងឲ្យការកើនឡើងទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស*

***ប្រភព :*** ទិន្នន័យទទួលបានពីអាជ្ញាធរកម្ពុជានិងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

***កំណត់សំគាល់ :*** - ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ *២០០៨-២០១០ (* ទិន្នន័យទាំងនេះអាចនឹងត្រូវបានកែប្រែឡើងវិញក្នុងពេលអនាគត *)*

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆមាសទី១-*២០១១*